# វគ្គទី២
# ការសិក្សា និង ជីវភាពនៅទីក្រុង
# (ទសវត្សរ៍ឆ្នាំ ១៩៦០-៧០)

មុនពេលដែលខ្ញុំត្រូវមករស់នៅៗទីក្រុងភ្នំពេញមួយឆ្នាំ ឪពុកខ្ញុំបានទិញផ្ទះឈើតូចមួយខ្នង ដើម្បីឲ្យបងប្រុសខ្ញុំទាំងពីរនាក់ស្នាក់នៅ និង បន្តការសិក្សា ។ ភ្នំពេញនាសម័យនោះជាទីក្រុងទំនើប ដែលមានគេអួតថាជាគុជនៃអាស៊ីភាគអាគ្នេយ៍ ។ អាគារសាធារណៈទាំងឡាយត្រូវសាងសង់ឡើងយ៉ាងមានរបៀបរៀបរយ និង មានការថែទាំយ៉ាងត្រឹមត្រូវ ។ ភ្នំពេញជាទីក្រុងតូចប្រចឡឹងដែលមានផ្លូវ ឬ វិថីខ្វាត់ខ្វែងប្រកបដោយចរាចរណ៍ឥតស្រាកស្រាន្ត ។ ក៏ប៉ុន្តែពួកយើងមិនបានរស់នៅក្នុងតំបន់ទាន់សម័យទាំងនោះទេ យើងរស់នៅក្នុងសង្កាត់ក្រីក្រមួយឈ្មោះថា "ផ្សារដើមគ" ។

## ផ្ទះឈើប្រក់សង្កសីនៅផ្សារដើមគ

នៅក្នុងសង្កាត់នេះយើងមិនមានភ្លើងអគ្គិសនី និង ទឹកស្អាតប្រើប្រាស់ទេ ។ ពេលយប់យើងអុជចង្កៀងប្រេងកាតដើម្បីបំភ្លឺ ជាពិសេស នៅពេលយើងអាន ឬ ធ្វើលំហាត់មេរៀនរបស់យើងតែប៉ុណ្ណោះ ។ យើងប្រើចង្ក្រានធ្យូង ដើម្បីចំអិនអាហារ ឯធ្យូងនោះយើងទិញពីផ្ទះចិននៅជិតខាងមកប្រើ ។ ពួកយើងទិញទឹកដែលគេអូសលក់ ពីផ្ទះមួយទៅផ្ទះមួយ ។ ទឹកនោះ គេដាក់ក្នុងធុងស៊ីតែន ឬ

ធុងសាំង ផ្ទុកនៅលើរ៉ឺម៉កអូសដោយកម្លាំងមនុស្ស ។ នៅទីក្រុងខុសពីនៅស្រុកស្រែ អ្វីៗក៏ត្រូវ ចំណាយប្រាក់ដែរគឺ គ្មានអ្វីដែលបានមកដោយទទេនោះទេ ។ នៅរដូវភ្លៀង ពួកយើងសន្សំសំចៃប្រាក់ខ្លះ ដោយយើងខំត្រងទឹកភ្លៀងយកមករក្សាទុកក្នុងពាងធំមួយ ។ មិនយូរប៉ុន្មានក្រោយមក ចរន្តអគ្គិសនីក៏បាន តភ្ជាប់តាមបណ្តាញមកដល់ផ្សារដើមគ ។

ផ្ទះឈើរបស់យើងមានទទឹង ៤ ម៉ែត្រ និង បណ្តោយ ៦ ម៉ែត្រ លើកខ្ពស់ផុតពីដី ដើម្បីអាចឲ្យយើងមានកន្លែងផ្នែកខាងក្រោមធ្វើជាផ្ទះបាយផង និង មានកន្លែងចងអង្រឹងមួយ ឬ ពីរបានផង ។ ជណ្តើរឈើឡើងទៅលើ នាំទៅរកយ៉តូចមួយទំហំ ១,៥ ម៉ែត្រ គុណ១,៥ ម៉ែត្រ ។ ផ្ទះឈើយើងនោះ មានតំបូលប្រក់ស័ង្កសី ។ យើងគ្មានបន្ទប់ទឹកអ្វីច្បាស់លាស់ទេ ។ នៅពេលយើងជំរះកាយ យើងប្រើផ្តិលងូតទឹកពាង ដែលយើងដាក់នៅក្រោមដើមក្រខុប ដែលជួយបាំងកំដៅថ្ងៃ ។ យើងដាក់ពាងទឹកព័ទ្ធដោយស្លឹកត្នោតចងភ្ជាប់ជាមួយបន្ទះឫស្សី កំពស់ត្រឹមចង្កេះ ដើម្បីធ្វើជាបន្ទប់ទឹករបស់ពួកយើង ។

យើងរស់នៅក្នុងបរិវេណដីទទឹង ១២ ម៉ែត្រ និង បណ្តោយ ២៤ ម៉ែត្រ ។ យើងធ្វើបង្គន់ចាក់ទឹកនៅចុងម្ខាងដីឯក្រោយផ្ទះ ។ ចំពោះពួកយើងដែលមកពីទីជនបទ មានបង្គន់បែបនេះ យើងគិតថាមានអនាម័យណាស់ទៅហើយ ។ អ្នកស្រុកដែលរស់នៅក្បែរខាងយើង ភាគច្រើនជាកម្មកររោងចក្រ អ្នកជាក់ស៊ីក្លូ ឬ មន្ត្រីរាជការតូចតាច។ តាមពិតយើងរស់នៅក្នុងតំបន់ដែលគ្មានអនាម័យគ្រប់គ្រាន់ទេ ។

ទឹកសំអុយដែលនៅតាមលូ ជាមួយនឹងបង្គន់បើកចំហបានជះឥតឈប់ឈរនូវក្លិនអាក្រក់ដែលមនុស្សធម្មតាពិបាកទ្រាំ ។ ទឹកសំអុយដែលត្រូវគាំងស្ទះដោយសំរាម ក៏ក្លាយទៅជាទីជម្រកនៃពពួកសត្វមូស ដែលកើតមានមីរដេរដាស ។ ដូច្នេះ នៅពេលយប់យើងត្រូវទទួលទានដំណេកនៅក្នុងមុង ការពារកុំឲ្យមូសខាំ ។

បើយើងធ្វើដំណើរចេញពីផ្លូវធំគឺ មហាវិថីម៉ៅសេទុង ដែលនៅជំនាន់នោះនៅមិនទាន់ចាក់កៅស៊ូនៅឡើយនោះ យើងត្រូវដើរតាមផ្លូវដ៏ចង្អៀតប្រវែងប្រមាណ ៣០០ ម៉ែត្រ ទើបទៅដល់ផ្ទះឈើរបស់យើង ។ នៅតាមដងផ្លូវចង្អៀតនេះមួយកំណាត់ យើងត្រូវឆ្លងកាត់ផ្សារដើមគ ដែលឈ្មួញរៀបចំលក់ដូររបស់របរចំណីចំណុក ម្ហូបអាហារគ្រប់មុខហូរហែ នៅក្រោមលំហមេឃ ។ បន្ទាប់ពីផ្សារ យើងដើរលើស្ពានឈើឆ្លងអូរ ឬ បឹងមួយដែលពោរពេញទៅដោយគំនរសំរាម ។ ផ្លូវសម័យនោះភាគច្រើនធ្វើលើដីឥដ្ឋ ។ នៅពេលភ្លៀងម្តងៗយើងជួបនឹងភាពប៉ប៉ិចប៉ប៉ាច់ ហើយត្រូវរអិលដួលស្ទើរចាប់មិនឈ្នះ ។ តំបន់យើងនេះ ក៏សម្បូរណ៍ទៅដោយជនទុច្ចរិត ចោរឆក់ ចោរលួចណាស់ដែរ ។ កាលពុំទាន់មានភ្លើងអគ្គិសនី នៅពេលយប់ងងឹតយូរៗម្តង យើងឃើញស្ត្រីលក់បង្អែមពពាយនាយលក់នំចំណីរបស់គាត់ដោយស្រែកថា៖ "ផ្លែអាយអើយផ្លែអាយ បាយដំណើបទ្រាប សណ្តែកបាយ សង្ខ្យាសែសយ" ។ល។ ដោយមានក្មេងកាន់ចង្កៀងបំភ្លឺផ្លូវដើរពីមុខផង ។ ពេលយប់យើងត្រូវលីទោចក្រយានរបស់យើងយកទៅដាក់លើផ្ទះ ការពារកុំឲ្យចោរលួច ។ ទ្វារ បង្អួចត្រូវបិទឲ្យជិត និង ដាក់គន្លឹះឲ្យជាប់ ទោះបីជាយើងពុំមានរបស់របរដ៏មានតម្លៃអ្វីឡើយ ។ នៅក្នុងផ្ទះគ្រឿងសង្ហារិម និង អសង្ហារិមរបស់យើងមានត្រឹមតែតុពីរ ទូឈើមួយ កៅអីបួន ឬ ប្រាំ និង គ្រែឈើមួយសម្រាប់បងទីមួយរបស់ខ្ញុំ ។ ខ្ញុំ និង បងស៊ីនឿន យើងចងមុងក្រាលកន្ទេលផ្ទាល់លើក្តារតែម្តង ។

# ជីវភាពប្រចាំថ្ងៃ

ក្នុងជីវភាពប្រចាំថ្ងៃរបស់យើងៗបែងចែកភារកិច្ចគ្នា ។ បងប្រុសទីមួយទទួលបន្ទុកចាត់ការទូទៅ រាប់តាំងពីការផ្គត់ផ្គង់ភ័ស្តុភាររហូតដល់ការថែទាំជួសជុលផ្ទះសម្បែង ។ បងប្រុសទីពីរ ទទួលបន្ទុកខាងម្ហូបអាហារ ឯចំណែកខ្ញុំ ជាជំនួយការ

គ្រប់បែបយ៉ាងដល់បងៗទាំងពីរ ។ នៅថ្ងៃសម្រាក យើងលាងសម្អាតទោចក្រយាន និង បោកខោអាវរៀងៗខ្លួន ។ នៅពេលដែលយើងជាប់រវល់យ៉ាងមមាញឹកក្នុងការសិក្សា យើងមិនធ្វើម្ហូបខ្លួនយើងទេ យើងទិញម្ហូបឆ្អិនស្រេចដែលគេដាក់លក់នៅរានលក់ម្ហូបថោកៗសំរាប់អ្នកជាក់ស៊ីក្លូ ។ កាលណាយើងដាំបាយឆ្អិនស្រេចបាច់ហើយយើងទៅទិញម្ហូប ជាពិសេសសម្លម្ជូរយួនដែលមានតម្លៃមួយចានថ្លៃបីរៀល ។ យូរៗទៅ ដោយយើងឧស្សាហ៍ទៅទិញសម្លនៅរានដដែលៗ ខ្ញុំក៏ត្រូវបានអ្នកស្រីម្ចាស់រានរាប់អាន ។ យើងទិញតែបីរៀល គាត់ដួសសម្លឲ្យស្ទើរតែពេញមួយចានយួរគ្រប់គ្រាន់ល្មមសំរាប់គ្នាទាំងបីនាក់ ។ នៅពេលដែលយើងជិតដាច់ស្បៀងម្តងៗ យើងនាំគ្នាទៅភូមិស្នាយពល ដើម្បីទៅដឹកយកមកភ្នំពេញនូវអង្ករ ត្រីងៀត ត្រីឆ្អើរ និង ប្រាក់ខ្លះ ។ ជាធម្មតា ឪពុកម្តាយខ្ញុំ ផ្តល់ប្រាក់ម្តងៗឲ្យពួកយើងប្រហែល ៥០ ឬ ៦០ រៀលតែប៉ុណ្ណោះ ។

ជួនកាល ឪពុកខ្ញុំគាត់មកលេងពួកយើងនៅភ្នំពេញ ដោយមិនបានប្រាប់មុន ។ ពេលគាត់មកលេងម្តងៗ ពួកយើងសប្បាយចិត្តណាស់ ព្រោះគាត់តែងនាំពួកយើងទៅទទួលទានអាហារ នៅហាងលក់ម្ហូបចិននៅ តាមដងមហាវិថីម៉ៅសេទុង ។ ម្តាយខ្ញុំមិនសូវមានឱកាសមកលេងទីក្រុងភ្នំពេញទេ ព្រោះជាប់រវល់មើលប្អូនៗតូចៗ ។

នៅសង្កាត់ផ្សារដើមគ ពួកយើងក៏មិនមែនរស់នៅតែឯកឯងនោះទេ ។ នៅប្រហែល ២០០ ម៉ែត្រពីផ្ទះយើង ក៏មានផ្ទះម្តាយធំខ្ញុំដែល មានកូនប្រុស ៣ នាក់រស់នៅជាមួយដែរ ។ ដូច្នេះជាញឹកញយ បងប្អូនជីដូនមួយរបស់យើងតែងមកលេងជាមួយពួកយើង ។ ជាពិសេស នៅក្រោយពេលបាយថ្ងៃត្រង់ ពួកយើងតែងចងអង្រឹង សំរាកអានមេរៀន ឬ បើពុំនោះទេ ពួកយើងនាំគ្នាលេងកីឡាពីងប៉ុង ។ នៅសម័យនោះ ពួកយើងនាំគ្នារៀនមេរៀនតាមរបៀបពីបុរាណគឺ ទន្ទេញមេរៀន

ឲ្យចាំមាត់ ។ ជិតពេលប្រឡងម្តងៗ យើងនាំគ្នាស្រែកទន្ទេញមេរៀនយ៉ាងឮៗគឺ ឮដល់ផ្ទះអ្នកជិតខាង អស់រាប់ម៉ោងក្នុងមួយថ្ងៃៗ ។ នៅសម័យនោះ ខ្ញុំហាក់ដូចជាមិនសូវខំប្រឹងរៀនសូត្រប៉ុន្មានឡើយ ។ ខ្ញុំច្រើនគេងលើអង្រឹង មើលមេរៀនហើយក៏ច្រើនលង់លក់លើអង្រឹង ដោយសៀវភៅធ្លាក់គ្របលើមុខជាញឹកញាប់ ។ បងជីដូនមួយខ្ញុំម្នាក់ ច្រើនតែឃើញខ្ញុំស្រមុកលើអង្រឹង ហើយតែងតែចោទសួរថា "ខ្ញុំមិនយល់សោះ តើមូលី រៀនមេរៀនរបៀបយ៉ាងដូចម្តេច បើឃើញតែរៀនដេកយ៉ាងនេះ ?"

# បានចូលរៀនវិទ្យាល័យ

នៅសាលារបស់ខ្ញុំគឺវិទ្យាល័យសង្គមរាស្ត្រនិយម ការសិក្សាចែកជាពីរផ្នែកៈ ផ្នែកបឋមភូមិស្ថិតនៅក្នុងវិទ្យាល័យទួលគោក ជាប់នឹងសាលាបឋមសិក្សា ពៅ អ៊ុម ឯផ្នែកមធ្យមភូមិស្ថិតនៅចំការមន ។ បងប្រុសទីមួយរបស់ខ្ញុំ គាត់តែងទៅរៀននៅចំការមន ចំណែកខ្ញុំៗទៅរៀននៅទួលគោក ។ រាល់ព្រឹកខ្ញុំចេញដំណើរពីផ្ទះទៅទិសខាងជើង ដោយជាក់កង់តាមមហាវិថីម៉ៅសេទុង ឆ្លងកាត់តាមមហាវិថីសហភាពសូវៀត បន្តតាមវិថីសម្តេច ប៉ែន នុត[21] រហូតដល់ខាងមុខមហាវិទ្យាល័យដូរតន្ត្រី[22] ។ កាលណាមកដល់អាគារមហាវិទ្យាល័យដូរតន្ត្រី ខ្ញុំតែងតែកំណត់ថាដល់ទីដៅហើយ ព្រោះអាគារវិទ្យាល័យរបស់យើងស្ថិតនៅក្បែរនោះ ។

---

[21] សម័យឥឡូវ វិថីនេះមានឈ្មោះថា វិថីសេនាប្រមុខ គិម អ៊ីល ស៊ុង ។

[22] ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ មានមហាវិទ្យាល័យតូរ្យតន្ត្រីមួយនៅម្តុំសាលា ពៅ អ៊ុម គេអាចសំគាល់បាន ដោយសារឧបករណ៍ភ្លេង ឬ ស្នូរភ្លេង ដែលពួកនិស្សិតហាត់លេងនៅទីនោះ ។

សាលារបស់យើង សាងសង់អំពីឈើប្រក់ក្បឿងខ្លះ ប្រក់ហ្វីប្រូស៊ីម៉ង់ខ្លះ ។ នៅក្នុងថ្នាក់រៀននីមួយៗ ប្រដាប់ប្រដារប្រើប្រាស់ ឬ គ្រឿងសង្ហារិម អសង្ហារិម ក៏មិនខុសគ្នាប៉ុន្មានពីថ្នាក់រៀន នៅសាលាឯភូមិស្នាយពលឡើយ ។ ខុសគ្នាតែនៅភ្នំពេញ ក្នុងថ្នាក់រៀន មានបំភ្លឺដោយភ្លើងអគ្គិសនី ។ សិស្សានុសិស្សភាគច្រើនធ្វើដំណើរមករៀនដោយជិះទោចក្រយានដូចខ្ញុំដែរ ។ សិស្សដែលមានឪពុកម្តាយជាអ្នកធូរធារ គេជិះម៉ូតូ(ទោចក្រយានយន្ត) ឬ អ្នកខ្លះជិះរថយន្តមកជាមួយឪពុកម្តាយរបស់គេ ឬ អ្នកខ្លះទៀត មានអ្នកបើកបរជូនដំណើរមកជាមួយ ។ តាមរយៈរបៀបរបបធ្វើដំណើរមករៀន គេអាចសំគាល់បាននូវឋានៈសង្គមខុសៗគ្នារបស់សិស្សានុសិស្សទាំងនោះ ។ ក្នុងន័យនេះ ស្ថានភាពសង្គមរបស់ខ្ញុំ អាចនិយាយបានស្ថិតនៅផ្នែកអ្នកក្រីក្រដែលជាភាគច្រើនជាងគេ ។ ក៏ប៉ុន្តែ បើពិនិត្យឲ្យស៊ីជម្រៅទៅខ្ញុំក៏នៅគ្រាន់បើជាងសិស្សខ្លះទៀតដែលគ្មានផ្ទះសម្បែង ហើយស្នាក់នៅជ្រកកោនតាមផ្ទះបងប្អូន ឬ នៅតាមវត្តអារាម ។ នៅសម័យនោះ ខ្ញុំមិនដែលនឹកដល់ការគស៊ូរវាងវណ្ណៈ និង វណ្ណៈអ្វីណាមួយឡើយ ។ ពួកយើងដែលជាអ្នកកាន់ព្រះពុទ្ធសាសនា មានជំនឿថា អ្នកមាន អ្នកក្រ អ្នកធំ ឬ អ្នកតូចមានភាពខុសគ្នាក៏អាស្រ័យដោយផលកម្មដែលគេសាងក្នុងជាតិមុន ឬ មានសំណាងក្នុងជាតិនេះ ។ បើជាតិនេះ យើងមានភាពទន់ទាប តែបើយើងខិតខំប្រឹងប្រែង យើងក៏អាចផ្លាស់ប្តូរវាសនាយើងបាន បើមិនបានក្នុងជាតិនេះ យើងនឹងគង់បានសម្រេចនៅជាតិក្រោយ ។ ជីវិត ឬ វាសនារបស់យើងត្រូវចាក់ពុម្ពឡើង ដោយការចាប់ជាតិឡើងវិញរបស់យើងម្នាក់ៗ ។

នៅភ្នំពេញ សាស្ត្រាចារ្យជាច្រើន ច្រើនតែជាស្ត្រី ។ អ្នកគ្រូៗទាំងនោះ ច្រើនតែជាភរិយារបស់មន្ត្រីជាន់ខ្ពស់ ឬ ពាណិជ្ជករ អ្នកមានៗ ។ ស្វាមីភរិយាខ្លះប្រកបរបរជាសាស្ត្រាចារ្យទាំងប្តីទាំងប្រពន្ធ ។ អ្នកទាំងនោះ បើករថយន្ត

មកធ្វើការ រីឯអ្នកខ្លះទៀត ត្រូវបានជូនដំណើរដោយអ្នកបើកបរដែលស្លៀកពាក់ឯកសណ្ឋានផង ។ លើកលែងតែបុគ្គលិកនៅការិយាល័យខ្លះ ខ្ញុំមិនដែលឃើញសាស្ត្រាចារ្យណាមកបង្រៀនដោយជិះកង់ ឬ ជិះម៉ូតូទេ ។ ពួកគាត់សុទ្ធតែមានរថយន្តស្ទើរតែគ្រប់ៗគ្នា ។ កាលនោះ មន្ត្រីណាដែលមានប្រពន្ធជាអ្នកគ្រូ សុទ្ធតែចាត់ទុកថាជាមនុស្សគ្រាន់បើ ។ មានប្រពន្ធជាអ្នកគ្រូ គ្រាន់បើជាងអ្នកដែលមានភរិយានៅផ្ទះធម្មតា ។

អ្នកគ្រូរបស់ខ្ញុំមួយចំនួន សុទ្ធតែធ្លាប់បានទៅរស់នៅឯប្រទេសបារាំងជាមួយស្វាមី ដែលមានខ្លះជានិស្សិតសាលាជាន់ខ្ពស់ ឬ ជាមន្ត្រីដែលត្រូវបានទៅរៀនសូត្របន្ថែម ឬ ត្រូវទៅធ្វើកម្មសិក្សា ។ កាលសម័យនោះ អ្នកធ្លាប់បានទៅបរទេសជាពិសេស ទៅប្រទេសបារាំង សុទ្ធតែត្រូវបានទទួលការគោរពរាប់អានខ្ពស់ជាងអ្នកនៅក្នុងស្រុក ។ គេច្រើនហៅអ្នកទាំងនេះថា "ជើងស្រុកបារាំង" ។ បើនៅស្រុកស្រែគ្រូបង្រៀនមានប្រជាប្រិយភាព នៅទីក្រុងអ្នក "ជើងស្រុកបារាំង" ក៏ប្រជាប្រិយណាស់ដែរ ។ យុវជនដូចជារូបខ្ញុំជាដើម តែងតែស្រមៃចង់ទៅស្រុកបារាំងជានិច្ច ។ អ្នកគ្រូៗរបស់ខ្ញុំទាំងនោះ និយាយភាសាបារាំងច្រើនជាងភាសាខ្មែរ ហើយស្លៀកពាក់តាមម៉ូតទំនើបៗទៀតផង ។

នៅឆ្នាំដំបូង ការសិក្សារបស់ខ្ញុំមានការលំបាកបន្តិច ។ វិលវល់នឹងជីវិតថ្មោងថ្មីនៅទីក្រុង ខ្ញុំប្រហែលជាត្រូវការពេលវេលាខ្លះ ដើម្បីឲ្យស៊ាំនឹងជីវភាពនេះ ។ នៅទីបញ្ចប់ឆមាសទី ១ ក្នុងចំណោមសិស្ស ៤០ នាក់ ខ្ញុំត្រូវទទួលចំណាត់ថ្នាក់ទី ២៣ ។ ក៏ប៉ុន្តែនៅចុងឆ្នាំ ខ្ញុំឡើងមកទី ១៨ វិញ ។ នៅទីក្រុងភ្នំពេញ ខ្ញុំឃើញមិត្តរួមថ្នាក់របស់ខ្ញុំ គេមានចំណេះដឹងទូទៅច្រើនជាងខ្ញុំ ដោយសារគេជាអ្នកទីក្រុង ។ ក៏ប៉ុន្តែ ទោះបីជាខ្ញុំមានប្រភពមកពីស្រែដែលគេហៅថាអ្នកស្រុកស្រែក៏ដោយ ក៏ខ្ញុំរៀនឈ្នះអ្នកទីក្រុងខាងផ្នែកតែងសេចក្តីជាភាសាបារាំងដែរ ។ ខ្ញុំនឹកមិនដល់ថា

ខ្ញុំអាចឈ្នះគេខាងផ្នែកវិជ្ជានេះសោះ ព្រោះតាមធម្មតាអ្នកនៅទីក្រុងត្រូវតែមានប្រៀបជាងយើងជានិច្ច ។ ក្នុងការតែងសេចក្ដីជាភាសាបារាំងនេះ បើសិស្សគ្រាន់បើគេទទួលពិន្ទុ ១១ ឬ ១២ ខ្ញុំទទួលបាន ១៣ ឬ ១៤ ។ អ្នកគ្រូខាងផ្នែកភាសាបារាំង តែងហៅខ្ញុំឲ្យឈរអានអត្ថបទរបស់ខ្ញុំ ដែលបានពិន្ទុល្អជាងគេ ឲ្យសិស្សទាំងអស់ស្ដាប់ ។ ខ្ញុំ មានមោទនភាពណាស់ចំពោះលទ្ធផលដ៏ល្អនេះ ទោះបីជាកាលសម័យនោះ ខ្ញុំនៅមិនទាន់និយាយបារាំងបានល្អនៅឡើយក៏ដោយ ។

# វិធីពង្រីកចំណេះខាងភាសាបារាំង

ដើម្បីហាត់និយាយបារាំងឲ្យបានស្ទាត់ល្អ ខ្ញុំតែងជិះកង់ទៅតំបន់វត្តភ្នំដែលមានជនជាតិបារាំងភាគច្រើនស្នាក់អាស្រ័យនៅ ។ តាមធម្មតាខ្ញុំតែងសង្កេតឃើញពួកបារាំងធ្វើដំណើរឡើងចុះ តាមដងផ្លូវ ឬ តាមសួនច្បារមុខវិទ្យាល័យបារាំងដេកាត (Descartes) ។ ពេលទៅដល់ទីនោះ ខ្ញុំផ្អែកទោចក្រយានរបស់ខ្ញុំទល់នឹងដើមក្រោកដ៏ធំ រួចឈរសម្ងំចាំមើលក្រែងមានបារាំងដើរមក ។ ពេលឃើញ ខ្ញុំស្រែកសួរជាភាសាបារាំងថា៖ "លោក លោកស្រី អញ្ជើញទៅណា? ឬ ថា លោក លោកស្រីឈ្មោះអ្វី?" ជាដើម ។ ជនជាតិបារាំងទាំងនោះហាក់ដូចជាភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះសំណួររបស់ខ្ញុំ ដែលមិនច្បាស់ នៅមានសំនៀងខ្មែរនៅឡើយ ។ នៅពេលខ្លះ នៅពេលបារាំងឆ្លើយមកវិញ ខ្ញុំស្ដាប់មិនបាន ព្រោះបារាំងនិយាយញាប់ពេក ។ ទោះជាយ៉ាងណាក្ដី ក្រោយពីបាននិយាយជាមួយបារាំងមួយម៉ាត់ ឬ ពីរម៉ាត់ ខ្ញុំក៏អស់ចិត្តដែរ ។ នៅថ្នាក់រៀនឯទៀត គេមានជនជាតិបារាំងជាគ្រូបង្រៀនភាសាបារាំង ដូច្នេះពួកសិស្សៗមិនពិបាកទៅហាត់រៀននិយាយភាសាបារាំងនៅវត្តភ្នំដូចខ្ញុំឡើយ ។

ការសិក្សានៅភ្នំពេញរបស់យើង ត្រូវបានផ្អាកជាញឹកញាប់ក្នុងមួយខែៗ ដោយសាររាជរដ្ឋាភិបាលត្រូវការនាំសិស្សានុសិស្សទៅចូលរួមក្នុងពិធីផ្សេងៗ ដូចជាធ្វើបដិសណ្ឋារកិច្ចទទួលអ្នកដឹកនាំនៃប្រទេសជាមិត្តនានា ដែលមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាយើង ។ នៅសម័យនោះ សង្គមរាស្ត្រនិយមក្រោមការដឹកនាំរបស់សម្តេច សីហនុ មានមិត្តភក្តិជាច្រើននៅក្នុងពិភពលោក ជាពិសេសក្នុង ចំណោមប្រទេសតតិយលោក ។ ក្នុងពិធីបដិសណ្ឋារកិច្ចនោះ ពួកយើងត្រូវស្លៀកពាក់ឯកសណ្ឋានយុវ័ន ដែលមានឈ្មោះពិតប្រាកដថា "យុវជនរាជសង្គមនិយមខ្មែរ" ។ ឯកសណ្ឋាននោះគឺ ខោអាវកាគីដៃវែង ជើងវែង ក្រវ៉ាត់កពណ៌ខ្មៅ និងព្យួរបន្តោងមានព្រះឆាយាលក្ខណ៍សម្តេច នៅហោប៉ៅអាវខាងលើខាងមុខផង ។ ឯកសណ្ឋានទាំងនោះ យើងត្រូវចំណាយប្រាក់ខ្លួនយើងដើម្បីទិញ ឬ កាត់នៅហាងចិនដែលមានដេរដាសនៅក្នុងរាជធានី ។ ដូច្នេះ យើងស្លៀកឯកសណ្ឋានសាលានៅថ្ងៃរៀនធម្មតា ឬ ស្លៀកពាក់ឯកសណ្ឋានយុវ័ន នៅពេលមានពិធីសំខាន់ៗ ។ បន្ថែម លើពិធីបដិសណ្ឋារកិច្ច យើងក៏ត្រូវចូលរួមជាញឹកញាប់ក្នុងបាតុកម្មផ្សេងៗ ដែលត្រូវបានរៀបចំឡើង ដើម្បីគាំទ្រសម្តេចឪព្រះប្រមុខរដ្ឋ ឬ ដើម្បីធ្វើការហត្ថកម្មជាច្រើនទៀតផង ។

## បានចូលសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ

មួយឆ្នាំក្រោយមក បងប្រុសទីមួយរបស់ខ្ញុំ ក៏ឈប់រៀននៅវិទ្យាល័យសង្គមរាស្ត្រនិយម ព្រោះគាត់ប្រឡងជាប់ចូលរៀននៅវិទ្យាស្ថានគរុកោសល្យនៅកំពង់កន្ទួតក្នុងខែត្រកណ្តាល ។ គាត់ត្រូវទទួលការបំពាក់បំប៉នវិជ្ជាគរុកោសល្យក្នុងរយៈពេលពីរឆ្នាំ មុននឹងចេញទៅបង្រៀនសិស្សតាមសាលា ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គាត់នៅតែតាមត្រួតពិនិត្យការសិក្សារបស់ខ្ញុំដែរ ។ ថ្ងៃមួយនៅពេល

វិស្សមកាល យើងធ្វើដំណើរទៅលេងស្រុកកំណើតរបស់យើង ឯភូមិស្នាយពលទាំងអស់គ្នា ។ បងប្រុសខ្ញុំហុចស្រោមសំបុត្រដ៏ធំមួយមកឲ្យខ្ញុំ ។ ក្នុងនោះមានឯកសារមួយចំនួន ជាពិសេស ពាក្យសុំប្រឡងចូលរៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដែលសម័យនោះ គេហៅទូទៅថា "សាលាពាណិជ្ជកម្ម" ។ ខ្ញុំមិនដែលដឹង មិនដែលឮឈ្មោះសាលានោះឡើយ ។ ម្យ៉ាងទៀតខ្ញុំក៏មិនយល់ថានៅពេលរៀនចប់អាចប្រកបការងារអ្វីដែរ ។ ឪពុកម្តាយខ្ញុំ ក៏ពុំមានប្រតិកម្មអ្វីចំពោះគំនិតរបស់បងប្រុសខ្ញុំនោះទេ ។ មុខវិជ្ជាពាណិជ្ជកម្មជាមុខវិជ្ជាដ៏ថ្មីសន្លាង សម្រាប់ពួកយើង ជាពិសេស ចំពោះឪពុកម្តាយខ្ញុំ ដែលតែងតែប្រាថ្នាឲ្យកូនចៅបានរៀនសូត្រ ដើម្បីបំរើការងារក្នុងរាជការ ជាជាងធ្វើការក្នុងវិស័យឯកជន ។ តាមធម្មតាអ្នកមានសញ្ញាប័ត្រខាងផ្នែកពាណិជ្ជកម្ម តែងរកការងារបានក្នុងក្រុមហ៊ុនឯកជន ច្រើនជាងក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ។ នៅទីបំផុត ខ្ញុំក៏យល់ព្រមត្រៀមខ្លួនប្រឡងចូលរៀននៅសាលាពាណិជ្ជកម្ម ឬ មហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ ក្នុងការប្រឡងចូលនេះគេរើសតែសិស្សចំនួន ៤០ នាក់តែប៉ុណ្ណោះ ក្នុងចំណោមបេក្ខជន ៧០០ នាក់ សំរាប់វគ្គសិក្សាកំរិតទីមួយ ។ មុខវិជ្ជាតែងសេចក្តីជាភាសាខ្មែរ ជាមុខវិជ្ជាមួយដែលអាចទទួលពិន្ទុច្រើនក្នុងការប្រឡងប្រជែង ។

ខ្ញុំមិនបានត្រៀមប្រឡងជាដុំកំភួនអ្វីទេ លើកលែងតែរំលឹកឡើងវិញនូវក្បួនលេខានព្វន្ត (Arithmétique) ខ្លះៗតែប៉ុណ្ណោះ ។ នៅក្នុងវិញ្ញាសាតែងសេចក្តីជាភាសាខ្មែរ មានប្រធានបទស្តីពីសកម្មភាពនៅក្នុងផ្ទះលក់ទំនិញមួយ ។ ដោយធ្លាប់មានទំនាក់ទំនងជាញឹកញាប់ជាមួយពួកពាណិជ្ជករចិននៅភូមិស្នាយពល ខ្ញុំរៀបរាប់បានក្បោះក្បាយល្អណាស់ អំពីជីវិតប្រចាំថ្ងៃយ៉ាងមមាញឹករបស់ចិនលក់ចាប់ហួយម្នាក់ឈ្មោះចិកសេង ។ តាមពិត ចិកសេង គ្រាន់តែជាឈ្មោះដែលខ្ញុំប្រឌិតឡើងជាតួអង្គសំខាន់នៅក្នុងការតែងសេចក្តីរបស់ខ្ញុំ សំរាប់ការប្រឡងប្រជែង

តែប៉ុណ្ណោះ ។

ខ្ញុំរៀបរាប់ថា ចិកសេង ជាមនុស្សឧស្សាហ៍ធ្វើការ ។ ជារៀងរាល់ថ្ងៃគាត់ភ្ញាក់ពីព្រលឹមប្រកបដោយទឹកមុខញញឹមជានិច្ច រង់ចាំទទួលភ្ញៀវ និង រៀបចំទុកដាក់ទំនិញរបស់គាត់ឲ្យមានរបៀបរៀបរយគួរជាទីគាប់ភ្នែក ។ នៅទីបំផុត ខ្ញុំក៏ប្រឡងជាប់ចូលរៀនមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ហើយខ្ញុំនឹកថាប្រហែលជាខ្ញុំបានពិន្ទុល្អក្នុងការតែងសេចក្តីស្តីអំពី ចិកសេង នោះពុំខានឡើយ ។

និស្សិតទាំង ៤០ នាក់ដែលបានទទួលជោគជ័យក្នុងការប្រឡងប្រជែងនេះចេញមកពីឋានៈសង្គមផ្សេងៗគ្នាគឺ ក្នុងចំណោមអ្នកស្រែចំការ មន្ត្រីរាជការ មន្ត្រីថ្នាក់ធំ និង គហបតីអ្នកមានទ្រព្យសម្បត្តិជាដើម ។ ក្នុងនោះ ខ្ញុំចាប់ផ្តើមរាប់អានគ្នាជាមិត្តភក្តិចាប់ពីអាទិត្យទីមួយ ជាមួយយុវនិស្សិតមួយចំនួន ដែលយូរៗទៅក៏ក្លាយទៅជិតស្និទ្ធជារៀងរហូតមក ។ ទីមួយ យុវតីពីរនាក់ ម្នាក់ឈ្មោះកញ្ញា អ៊ឹង កនិដ្ឋា ជាកូនស្រីរបស់លោក អ៊ឹង អ៊ី ជាមន្ត្រីធំក្នុងព្រះបរមរាជវាំង ធ្លាប់កាន់តំណែងជារដ្ឋមន្ត្រី[23] ថ្នាក់អគ្គមហាសេនា និង អភិបាលខេត្តជាច្រើនដង ។ ម្នាក់ទៀតគឺកញ្ញា កែវ សូដារ៉ា ជាសាច់ញាតិរបស់មហាសេដ្ឋីក្នុងស្រុកម្នាក់ ។ អ្នកទាំងពីរធ្វើដំណើរមករៀន ដោយមានអ្នកបើកបរក្នុងឯកសណ្ឋានបររថយន្តជូនមករាល់ថ្ងៃ ។ កញ្ញាទាំងពីរសុទ្ធតែបានរៀននៅសាលាបារាំងគឺ ម្នាក់នៅវិទ្យាល័យដេកាត (Descartes) និង ម្នាក់ទៀតនៅសាលាដូនជីកាតូលិកឯទីក្រុងកែប ។ អ្នកទាំងពីរនិយាយភាសាបារាំងយ៉ាងស្ទាត់ជំនាញ និង យ៉ាងច្បាស់លាស់ ។ ក្នុងចំណោមប្រុសៗ ខ្ញុំស្គាល់យុវជនម្នាក់ឈ្មោះ អ៊ុំ មន្ថា ដែលមានឪពុកជាតម្រួតក្រុង ។

---

[23] Ministère de l 'Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, Phnom Penh, 1970, p. 34. (ឯ. ឧ. អ៊ឹង អ៊ី មានតួនាទីជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ថ្នាក់អគ្គមហាសេនាដែលមានឋានៈធំជាងគេក្នុងកុង្សីយ៍សេនាបតី (Conseil des Ministres) គឺស្មើរដ្ឋមន្ត្រីទី១ ពីថ្ងៃទី ១៨ មីនា ដល់ ១៣ សីហា ១៩៤៥ ក្នុងគណៈរដ្ឋមន្ត្រីដឹកនាំផ្ទាល់ដោយព្រះមហាក្សត្រព្រះករុណាព្រះបាទ នរោត្តម សីហនុ)

មិត្តម្នាក់នេះជិះម៉ូតូហុងដាមករៀន ហើយតែងតែបបួលពួកយើងទៅទទួលទានគុយទាវរាល់ព្រឹកនៅភោជនីយដ្ឋានក្បែររោងអ្នកតាចិន ដែលនៅមិនឆ្ងាយពីសាលារបស់យើងនោះ ។ រាល់ៗដង នៅពេល មន្ថា បបួលពួកយើងទៅញ៉ាំគុយទាវ ពួកយើងមិនដែលប្រកែកទេ ហើយតែងនឹកក្នុងចិត្តថាមុខរបរជាតម្រួតក្រុង (នគរបាលក្រុង) របស់ឪពុកមន្ថា ប្រហែលជារកប្រាក់ចំណូលបានច្រើនណាស់ ទើបកូនមានលុយកាក់ចាយវាយឥតឈប់ឈរជារៀងរាល់ថ្ងៃ ។ ក៏ប៉ុន្តែតាមពិតមិនមែនឪពុកមន្ថាទេ ដែលជាអ្នកផ្តល់ប្រាក់កាសឲ្យគឺ បងស្រីរបស់មន្ថាម្នាក់ដែលជាអ្នករាំរបាំព្រះរាជទ្រព្យ ដែលតែងតែផ្តល់ប្រាក់កាសដល់ មន្ថា មិនដែលដាច់ ។ បងស្រីនោះជាគូកំណាន់ចិត្តរបស់មន្ត្រីធំម្នាក់ នៅក្នុងព្រះបរមរាជវាំង ដែលជាអ្នកមានសម្បត្តិស្តុកស្តម្ភ ។ មន្ថា ចូលចិត្តទុកសក់វែងដូចពួកហ៊ីពី ស្លៀកខោជីន (Jean) ឬខោជើងធំមិនដែលខាន ។

ក្នុងចំណោមមិត្តភ័ក្តិទាំងអស់ ខ្ញុំនៅក្មេងជាងគេ ។ ក្រៅពីនោះយើងមានមិត្តពីរនាក់ទៀត មានអាយុចាស់ជាងគេនៅក្នុងថ្នាក់គឺ ស៊ុន សារ៉ុម និង នូ វ៉ាន់ថន ។ សារ៉ុម វ៉ាន់ថន មន្ថា និង ខ្ញុំ យើងជាមិត្តជិតស្និទ្ធណាស់ ។ ឪពុកសារ៉ុមជាបសុពេទ្យ ដូចនេះ គ្រួសារសារ៉ុមពុំមានបញ្ហាហិរញ្ញវត្ថុអ្វីទេ ។ សារ៉ុមជាមនុស្សខ្ជិល ។ ក៏ប៉ុន្តែ សម័យនោះ ពួកយើងមិនសូវចាប់អារម្មណ៍ពីលក្ខណៈផ្លូវភេទរបស់គាត់ប៉ុន្មានទេ យើងគ្រាន់តែនិយាយចំអន់លេង ពីអាកប្បកិរិយាមាយាម្ទិកម៉ូក់ដូចស្រីរបស់គាត់តែប៉ុណ្ណោះ ។ សារ៉ុម និង មន្ថា ដើរជាមួយគ្នាជានិច្ចមិនសូវនៅបែកគ្នាឡើយ ។ វ៉ាន់ថន មានជីវភាពខ្សត់ខ្សោយដូចខ្ញុំដែរ ។ មុននឹងបានមកចូលរៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រនេះ វ៉ាន់ថន ប្រកបរបរជាអ្នកប្រដាល់ដើម្បីរកប្រាក់មកចិញ្ចឹមម្តាយចាស់ និង ប្អូនស្រីរបស់គាត់ ។ ខ្ញុំតែងដើរជាមួយវ៉ាន់ថនជានិច្ច ដោយសារផ្ទះយើងទាំងពីរនៅជិតគ្នា ។ វ៉ាន់ថន គ្មានមធ្យោបាយធ្វើ

ដំណើរ ខ្ញុំមានទោចក្រយានកញ្ចាស់មួយ ។ ដូច្នេះ យើងប្រវាស់ដៃគ្នាគឺ វ៉ាន់ថន ជាអ្នកជាក់កង់ ឯខ្ញុំចាំជិះពីក្រោយ ។ គាត់ប្រើកម្លាំង ឯខ្ញុំដាក់ទោចក្រយានរបស់ខ្ញុំឲ្យប្រើរួមគ្នា ។

មុខវិជ្ជាដែលពួកយើងរៀនមានមុខវិជ្ជាគណនេយ្យ ពាណិជ្ជកម្ម ច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម (ច្បាប់ទាំងពីរនេះ យើងរៀនគោលធំៗ មិនបានស៊ីជម្រៅប៉ុន្មានទេ) វិទ្យាសាស្ត្រសេដ្ឋកិច្ច និង នព្វន្តសាស្ត្រដែលទាក់ទងនឹងសកម្មភាពពាណិជ្ជកម្មជាដើម ។ សាស្ត្រាចារ្យសុទ្ធសឹងជាមន្ត្រីជាន់ខ្ពស់ ដែលមានបទពិសោធន៍ក្នុងមុខងារសាធារណៈ ក៏ដូចជាមុខងារក្នុងវិស័យឯកជន ។ សាស្ត្រាចារ្យខ្លះធ្លាប់កាន់ ឬ កំពុងកាន់តំណែងជារដ្ឋមន្ត្រីក្នុងរាជរដ្ឋាភិបាល ។ អស់លោកទាំងនោះ មានសញ្ញាប័ត្រជាន់ខ្ពស់មកពីបរទេស ជាពិសេសមកពីប្រទេសបារាំង ។ ពួកគាត់សុទ្ធតែមានការងារធ្វើនៅច្រើនកន្លែងគឺ ធ្វើការប្រចាំក្រសួងផង បង្រៀននៅតាមមហាវិទ្យាល័យផង ។ លោកសាស្ត្រាចារ្យខ្លះបង្រៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រផង និង នៅមហាវិទ្យាល័យនិតិសាស្ត្រ និង សេដ្ឋសាស្ត្រផង ។

នៅពេលដែលខ្ញុំចូលរៀននោះលោក ខៀវ សំផន ដែលជាសាស្ត្រាចារ្យម្នាក់ទើបនឹងបាត់ខ្លួនពីរាជធានី ។ ដូច្នេះ ខ្ញុំគ្រាន់តែឮឈ្មោះគាត់តែប៉ុណ្ណោះ ។ លោក ខៀវ សំផន មានឈ្មោះល្បី ព្រោះគាត់មានឈ្មោះក្នុងចំណោមអ្នកដឹកនាំខ្មែរក្រហម ។ ខុសស្រឡះពីអស់លោកសាស្ត្រាចារ្យឯទៀត ដែលមានអ្នកបើករថយន្តជូនដំណើរមកធ្វើការរៀងរាល់ថ្ងៃ ពីមាត់មួយទៅមាត់មួយ ខ្ញុំឮថាគាត់មកបង្រៀនដោយជិះទោចក្រយានយន្តវ៉េស្ប៉ា (Vespa) កញ្ចាស់មួយ ទោះបីជាគាត់មានឋានៈខ្ពង់ខ្ពស់ក៏ដោយ រហូតដល់ពេលគាត់ទិញបានរថយន្តចំណាស់បន្តិច ម៉ាកវ៉ុលវ៉ាហ្គែន (Volkwagen) ។ ក្នុងអាយុជាងសាមសិបឆ្នាំ លោក ខៀវ សំផន នៅលីវ ។ ផ្ទុយពីលោក ខៀវ សំផន យើងមានព្រឹទ្ធបុរសរងម្នាក់ដែលនៅលីវដែរ តែចូលចិត្ត

ប្រើរថយន្តកីឡា (Sport) បើកជំបូល ។ ពួកនិស្សិតខ្សឹបៗគ្នាថាលោកព្រឹទ្ធបុរសរូងរូបនេះ ដើរលេងបារនៅម្តុំផ្សារធំថ្មីទល់ៗភ្លឺមិនដែលខានឡើយ ។

ក្នុងការសិក្សាជាដំបូង ខ្ញុំជួបនឹងការលំបាកជាច្រើន ដោយសារមុខវិជ្ជាទាំងឡាយសុទ្ធតែថ្មីសន្លាង សំរាប់ខ្ញុំទាំងអស់ ។ ក៏ប៉ុន្តែ នៅទីបញ្ចប់ឆ្នាំទីមួយ ខ្ញុំក៏បានក្លាយទៅជានិស្សិតពូកែម្នាក់នៅក្នុងថ្នាក់ ។ នៅពេលនោះ ខ្ញុំនឹកប្រដូចខ្លួនខ្ញុំដូចជាវត្ថុរឹងអ្វីមួយដែលត្រូវគេបោះទៅក្នុងទឹក ។ ជាដំបូង វត្ថុនោះធ្លាក់ទៅដល់បាតខាងក្រោម តែក្រោយមកបន្តិចម្តងៗ វត្ថុនោះក៏ងើបឡើងលើរហូតដល់អណ្តែតលើផ្ទៃទឹកវិញ ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលជាងគេម្តងទៀតគឺ ខ្ញុំរៀនឈ្នះមិត្តរួមថ្នាក់ទាំងអស់ ខាងផ្នែកភាសាបារាំង ទោះជាអ្នកខ្លះធ្លាប់រៀននៅវិទ្យាល័យដេកាត ឬ វិទ្យាល័យបារាំងឯទៀតក៏ដោយ ។

# គន់មើលសិស្សនារីវិទ្យាល័យដេកាត

នៅសម័យនោះ ពួកយើងមានអ្នកគ្រូជនជាតិបារាំងម្នាក់ ឈ្មោះអ្នកស្រីនីកូល ប៉ែរីយេ (Nicole Berrier) ។ ពួកយើងរៀនពីគាត់នូវមុខវិជ្ជាសំខាន់ៗដូចជាក្បួនវេយ្យាករណ៍ និង ការសរសេរសំបុត្រឆ្លើយឆ្លងខាងផ្នែកពាណិជ្ជកម្មជាភាសាបារាំង ។ ចាប់តាំងពីខ្ញុំបានចូលរៀននៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រមក ខ្ញុំមិនចាំបាច់ទៅចាំស្ទាក់និយាយភាសាបារាំង ជាមួយជនជាតិបារាំង នៅឯវត្តភ្នំទៀតទេ ។ ព្រោះខ្ញុំព្យាយាមនិយាយជាមួយអ្នកគ្រូខ្ញុំផ្ទាល់តែម្តង ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកយើងនៅតែបន្តទៅដើរលេងនៅតាមតំបន់វត្តភ្នំតទៅទៀតដែរ ។ នៅពេលសម្រាក ពួកយើងនាំគ្នាទៅមើលសិស្សនារីៗនៃវិទ្យាល័យដេកាត លេងកីឡាបាល់បោះ ឬ បាល់ទះ ក្នុងសំលៀកបំពាក់ខោខ្លីអាវខ្លីរបស់នាង ដែលបញ្ចេញសាច់ភ្លៅរាងស្រឡូកស្រឡូន ធ្វើឲ្យពួកយើងជក់អារម្មណ៍យ៉ាងខ្លាំង ។ នៅពេលនោះ ខ្ញុំ

ពុំបានដឹងថាពួកសិស្សនារីៗទាំងនោះ ពាក់ស្រោមជើងវែងជាប់សាច់ ដែលបារាំងហៅថាកុលឡង់ (Collant) នោះឡើយ ។

# អាហាររូបករណ៍ពីរាជរដ្ឋាភិបាល

នៅបំណាច់ឆ្នាំទីមួយ ខ្ញុំដាក់ពាក្យសុំអាហាររូបករណ៍ពីរាជរដ្ឋាភិបាលដោយសារតែជីវភាពរបស់ខ្ញុំកាន់តែដុនដាបទៅ ។ ក្រោយពីឆ្នាំសិក្សាទីពីរចាប់ផ្តើមបានប៉ុន្មានសប្តាហ៍ ខ្ញុំក៏ទទួលដំណឹងល្អថាក្រសួងសិក្សាធិការបានសំរេចផ្តល់អាហាររូបករណ៍ឲ្យខ្ញុំចំនួន ៦០០ រៀល[24] ក្នុងមួយត្រីមាស ។ ថ្ងៃនោះ ដោយត្រេកអរពេកខ្ញុំក៏ប្រញាប់ប្រញាល់ធ្វើដំណើរទៅភូមិស្នាយពល ដើម្បីនាំដំណឹងដ៏ល្អនេះទៅជំរាបឪពុកម្តាយខ្ញុំ ។ ម្តាយខ្ញុំមានការរីករាយជាខ្លាំង ព្រោះអាហាររូបករណ៍នេះនឹងជួយសំរាលបន្ទុកដ៏ធ្ងន់ធ្ងររបស់ក្រុមគ្រួសារយើង ។

នៅថ្ងៃបើកប្រាក់លើកទីមួយមកដល់ ខ្ញុំបបួលបងប្រុសខ្ញុំទាំងពីរនាក់ ទៅដើរលេងកំសាន្តនៅទីក្រុងភ្នំពេញទាំងអស់គ្នា ។ បងឈឿន ធ្វើដំណើរពីកំពង់កន្ទួតមកភ្នំពេញ ដើម្បីចូលរួមជាមួយពួកយើង ។ គាត់ទើបទិញបានទោចក្រយានយន្តកញ្ចាស់មួយ ។ ដូច្នេះ ក្នុងដំណើរកំសាន្តក្នុងក្រុងភ្នំពេញ ពួកយើងជិះម៉ូតូមួយទាំងបីនាក់ ។ យើងនាំគ្នាចូលភោជនីយដ្ឋាន ស្រស់ស្រូបអាហារឆ្ងាញ់ៗ ចូលហាងលក់ខោអាវ និង ចូលទស្សនាខ្សែភាពយន្ត ។ នៅសម័យនោះ ច្បាប់ចរាចរណ៍ត្រូវបានអនុវត្តបានត្រឹមត្រូវបង្គួរដែរ ។ តាមច្បាប់ចរាចរណ៍ យើងអាចជិះទោចក្រយានយន្តបានតែពីរនាក់ប៉ុណ្ណោះគឺ អ្នកបើកបរម្នាក់ និង អ្នកជិះខាងក្រោយម្នាក់ទៀត ។ បើប្រព្រឹត្តល្មើស យើងនឹងទទួលពិន័យពីតម្រួតក្រុងយ៉ាងធ្ងន់ធ្ងរ ។ ដូច្នេះ ពួកយើង

---

[24] មានតម្លៃស្មើ២០ដុល្លារ ដែលអាចទិញគុយទាវបានច្រើនចាន ព្រោះគុយទាវមួយចានថ្លៃតែ ៣ ទៅ ៥ រៀលប៉ុណ្ណោះ ។

ទាំងបីនាក់ត្រូវនាំគ្នាឃ្លាំមើលជៀសវាងកុំឲ្យជួបនឹងតម្រួត ។ យើងត្រូវលបមើលពីចម្ងាយ ។ នៅទីណាដែលមានតម្រួត គ្នាយើងម្នាក់ត្រូវចុះដើររហូតដល់ផុតឆ្ងាយពីក្អែកតម្រួតនោះ ទើបលោតឡើងជិះម៉ូតូវិញ ។ អាហារូបករណ៍នោះមានចំនួនតិចតួចទេ តែសម័យនោះ ចំពេលដែលយើងកំពុងខ្វះខាត អាហាររូបករណ៍នេះបានធ្វើឲ្យពួកយើងសប្បាយរីករាយឥតឧបមា ។

បន្ថែមលើការសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ខ្ញុំនៅព្យាយាមទៅរៀនភាសាចិនរាល់ល្ងាច នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ នៅសម័យនោះ ស្ថានទូតចិន ស្ថានទូតរុស្សី ស្ថានទូតអាល្លឺម៉ង់ សុទ្ធតែបានរៀបចំបង្រៀនភាសារៀងៗខ្លួន នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយមិនចាំបាច់បង់ប្រាក់ឡើយ ។ចាប់ពីម៉ោង ៨ ល្ងាចទៅ ខ្ញុំចូលទៅរៀនភាសាចិនជាមួយលោកគ្រូជនជាតិចិន ដែលត្រូវបញ្ជូនមកពីទីក្រុងប៉េកាំង ។ លោកគ្រូចិនទាំងនោះនិយាយភាសាខ្មែរបានច្បាស់ល្អណាស់ ហើយភាគច្រើនសុទ្ធតែបានរៀននៅមហាវិទ្យាល័យអក្សរសាស្ត្រនៅរាជធានីភ្នំពេញ ។ អស់រយៈពេលមួយខែ ខ្ញុំចាប់ផ្តើមចេះនិយាយខ្លះៗ និង ចេះច្រៀងចំរៀងជាភាសាចិនមួយបទ ដែលលោកគ្រូនិយាយថាជាព្រះរាជនិពន្ធរបស់សម្តេចឪ និង ដែលត្រូវគេយកទៅបកប្រែជាភាសាចិន ។ ខ្ញុំទើបរៀនភាសាចិនបានមួយខែ ក៏មានព្រឹត្តិការណ៍មួយដ៏សំខាន់បានកើតឡើងនៅប្រទេសចិនគឺ បដិវត្តន៍វប្បធម៌ដែលបានបង្ខំឲ្យលោកគ្រូចិន ត្រឡប់ទៅស្រុករបស់ពួកគាត់វិញអស់ លែងបានបង្រៀនតទៅទៀត ។ ចាប់តាំងពីពេលនោះមក ខ្ញុំក៏ពុំមានឱកាសបានទៅរៀនភាសាចិនទៀតដែរ ។

# ប្រឡងចេញយកសញ្ញាប័ត្រជាប់លេខ១

ការសិក្សាកំរិតទីមួយ នៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រត្រូវប្រើរយៈពេលពីរឆ្នាំ ។ នៅទីបញ្ចប់ និស្សិតត្រូវប្រឡងយកសញ្ញាប័ត្រមួយបញ្ជាក់ពីការសិក្សាផ្នែកពាណិជ្ជសាស្ត្រ ដែលអាចជាជំនួយក្នុងការស្វែងរកការធ្វើទៅអនាគត ។ នៅជិតថ្ងៃប្រឡងសញ្ញាប័ត្រមួយថ្ងៃ នៅពេលដែលពួកយើងកំពុងហ្វឹកហាត់ ដើម្បីត្រៀមខ្លួនចូលប្រឡងយ៉ាងសកម្មនោះ សារ៉ុម ផ្តល់យោបល់ថា ដើម្បីប្រឡងឲ្យជាប់ពួកយើងត្រូវរៀបចំធ្វើពិធីសែនអ្នកតានៅក្នុងសាលា ។ យើងមិនត្រូវធ្វើមិនដឹងមិនឮអំពីឫទ្ធីបារមីរបស់អ្នកតានោះឡើយ ។ សំណែនមានក្បាលជ្រូក និង គ្រឿងស្រវឹងសុរា ស្រាបៀរជាដើម ។

មហាវិទ្យាល័យពាណិជ្ជសាស្ត្រតាំងនៅក្បែរព្រះសក្យមុនីចេតិយ ដែលនៅពីមុខស្ថានីយរថភ្លើង ។ នៅក្នុងបរិវេណសាលាផ្នែកខាងជើង មានដើមចេកដុះច្រូងប្រាងស៊ុបទ្រុប ។ នៅកណ្តាលទីធ្លាសាលា មានដើមពោធិមួយដើមដែលមានអាយុជាងមួយរយឆ្នាំដុះយ៉ាងខ្ពស់ ហើយដែលមានរោងអ្នកតាមួយនៅខាងក្រោម ។ នៅក្នុងបរិវេណនេះ ក៏មានកម្មករសោលាមួយគ្រួសាររស់នៅជាប្រចាំដែរ ។ កាលពីពេលមុន និស្សិតជាច្រើនជំនាន់ ធ្លាប់បានមកធ្វើពិធីសែនបន់ស្រន់សុំជ័យជំនះពីអ្នកតានេះដែរ ។ ដូច្នេះពួកយើងក៏សំរេចថាមិនត្រូវបំភ្លេចប្រពៃណីនេះទេ ។

នៅយប់នោះ សារ៉ុម ជាអ្នករៀបចំគ្រឿងសំណែន ហើយនាំយកទៅក្នុងបរិវេណសាលា ។ ពិធីសែនបន់ស្រន់ចាប់ផ្តើមនៅម៉ោង ៩ យប់ ក្នុងរាត្រីដ៏ស្ងាត់ជ្រងំក្រោមពន្លឺនៃចង្កៀងអគ្គិសនីមូលតូចមួយ ។ យើងម្នាក់ៗធ្វើការបួងសួងសុំឲ្យបារមីអ្នកតាជួយឲ្យពួកយើងប្រឡងជាប់ ។ តាមធម្មតា យើងត្រូវមានអាចារ្យនាំមុខនៅក្នុងពិធីក្រៅព្រះពុទ្ធសាសនានេះ តែពេលនោះយើងពុំមានអាចារ្យទេ ។ មួយ

ស្របក់ក្រោយមក យើងក៏បែកគ្នាដោយទុកគ្រឿងសំណែនទាំងអស់នៅក្រោមដើមពោធិនៅមុខអ្នកតា ។ ពួកយើងនឹកថាគ្រឿងសំណែនដែលមានក្បាលជ្រូក និងស្រាបៀរប្អូនដប់ដបដែលយើងមិនទាន់គាស់បើកផងនោះ នឹងបានទៅជាអាហារដ៏ប្រណិតសំរាប់គ្រួសារកម្មករសាលា ដែលរស់នៅជាប្រចាំក្នុងបរិវេណនោះមិនខានឡើយ ។ ខ្ញុំនឹកក្នុងចិត្តថា គំនិតនាំឲ្យមានពិធីបន់ស្រន់អ្នកតានេះ ប្រហែលជាចេញពីកម្មករសាលានោះ ព្រោះជាទម្លាប់ដែលគាត់តែងនាំឲ្យធ្វើជាយូរមកហើយ ។ នៅទីបំផុត ពួកយើងក៏ប្រឡងជាប់មែន ។ តែនៅក្នុងចិត្ត ខ្ញុំនៅតែគិតថាពួកយើងប្រឡងជាប់ ដោយសារការខំប្រឹងប្រែងរបស់យើង មិនមែនដោយសារការបន់ស្រន់នោះឡើយ ។ ខ្ញុំប្រឡងបានលេខ ១ ក្នុងចំណោមនិស្សិតដែលបានប្រឡងជាប់នាសម័យប្រឡងលើកទីមួយចំនួន ១៩ នាក់ ។ មន្ថា ជាប់លេខ ៣ សារ៉ុម ជាប់លេខ ៥ វ៉ាន់ថន លេខ ៩ ។ មិត្តនារីទាំងពីរនាក់គឺ កន្និដ្ឋា និង សូដារ៉ា ប្រឡងពុំបានជាប់ដូចបំណងនៅលើកនេះទេ តែបានទទួលជោគជ័យនៅលើកក្រោយគឺ នៅសម័យប្រឡងទីពីរ ដែលប្រព្រឹត្តនៅប៉ុន្មានខែក្រោយមក ។ ជាមួយនឹងជោគជ័យជាប់លេខ ១ ក្នុងការប្រឡងយកសញ្ញាប័ត្រសិក្សាពាណិជ្ជកម្មកំរិតមួយនេះ ខ្ញុំក៏ប្រឡងជាប់លេខ ១ សម្រាប់ទទួលយកវិញ្ញាបនប័ត្រសិក្សារបស់រដ្ឋផ្នែកគណនេយ្យដែរ ។

តាមធម្មតាកាលណាយើងទទួលសញ្ញាប័ត្រសិក្សាខាងពាណិជ្ជកម្ម យើងត្រូវចេញទៅរកការងារនៅក្នុងក្រុមហ៊ុនរដ្ឋ ឬ ឯកជន ព្រោះតាមផ្លូវបច្ចេកទេស ការសិក្សាកំរិតនេះ គ្រាន់តែជាការបំប៉នមុខវិជ្ជាជីវៈ ឲ្យក្លាយទៅជាបុគ្គលិកការិយាល័យ ឬ គណនេយ្យថ្នាក់ក្រោម និង ថ្នាក់កណ្តាលរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ មិនមែនជាការសិក្សាដើម្បីឈានទៅរកសញ្ញាប័ត្រជាន់ខ្ពស់តទៅទៀតឡើយ ។ ក៏ប៉ុន្តែចំពោះខ្ញុំៗនៅមិនទាន់ចង់ចេញទៅធ្វើការអ្វីទេ ខ្ញុំចង់បន្តការសិក្សាជាន់ខ្ពស់តទៅទៀត ។ ក្នុងករណីនេះ ខ្ញុំត្រូវដាក់ពាក្យប្រឡងចូលរៀននៅកំរិតទីពីរតទៅទៀត ។

ដោយសារខ្ញុំជានិស្សិតចាស់ប្រចាំសាលា ខ្ញុំអាចជ្រើសរើសវិញ្ញាសាប្រឡងចូលបាន ដោយមិនបាច់ធ្វើតេស្តខាងនព្វន្តសាស្ត្រទេ តែត្រូវធ្វើតេស្តខាងគណនេយ្យ ។ ខ្ញុំនឹកថាខ្ញុំពូកែខាងវិជ្ជាគណនេយ្យ ដូច្នេះខ្ញុំគ្មានបារម្ភអ្វីចំពោះការធ្វើតេស្តនេះទេ ។ ក៏ប៉ុន្តែ អ្វីដែលខ្ញុំជឿថាខ្លាំង ក៏ប្រែក្លាយទៅជាខ្សោយទៅវិញ ។ ខ្ញុំធ្លាក់តេស្តខាងផ្នែកគណនេយ្យ ដែលនាំឲ្យបរាជ័យក្នុងការប្រឡងចូលរៀនបន្តនៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ យ៉ាងនេះហើយទើបខ្ញុំត្រូវបង្ខំចិត្តស្វែងរកការងារដោយខ្លួនឯង ។ ដោយជាប់រវល់ត្រៀមប្រឡងចូលរៀនបន្តនោះ ខ្ញុំមិនបានគិតគូររកការងារធ្វើភ្លាមៗដូចមិត្តភក្តិឯទៀតទេ ។ ឥឡូវមិត្តភក្តិទាំងអស់នេះ គេសុទ្ធតែបានការងារធ្វើជាលេខាធិការ ឬ ជំនួយគណនេយ្យករនៅក្រុមហ៊ុនរដ្ឋ "សុរាគារខ្មែរ" តាមរយៈកនិដ្ឋា ដែលមានគូដណ្តឹងជាប្រធានផ្នែកហិរញ្ញវត្ថុ និង ផ្នែកគណនេយ្យរបស់ក្រុមហ៊ុនរដ្ឋនេះ ។ ខ្ញុំត្រូវស្វែងរកការងារធ្វើដោយខ្លួនឯង ។ ខ្ញុំក៏ដាក់ពាក្យសុំរកការងារធ្វើនៅក្រសួងការងារ និង សង្គមកិច្ច ។

## ជីវិតក្នុងពិភពកម្មករ

ថ្ងៃមួយនៅពេលខ្ញុំទៅលេងភូមិស្នាយពល ខ្ញុំស្តាប់វិទ្យុជាតិ ។ ខ្ញុំឮគេហៅឈ្មោះខ្ញុំឲ្យទៅមើលប្រកាសស្តីពីលទ្ធផលនៃការដាក់ពាក្យរបស់ខ្ញុំ ។ នៅពេលត្រឡប់ទៅភ្នំពេញវិញ ទើបខ្ញុំដឹងថាខ្ញុំត្រូវបានទទួលឲ្យចូលធ្វើការជាជំនួយគណនេយ្យករ នៅរោងចក្ររដ្ឋធ្វើកែវនៅជើងឯក ក្បែររាជធានី ។ ក្នុងតួនាទីជាជំនួយការគណនេយ្យករនេះ ខ្ញុំនឹងត្រូវទទួលប្រាក់ប្រចាំខែចំនួនប្រហែល ៤០ ដុល្លារស.រ.អា ។ ខ្ញុំធ្វើការនៅរោងចក្ររដ្ឋធ្វើកែវតែមួយខែតែប៉ុណ្ណោះ ចាប់ពីខែ កញ្ញា ដល់ខែ តុលា ១៩៦៨ ព្រោះប្រាក់ខែ ៤០ ដុល្លារនោះ មិនគ្រប់គ្រាន់សំរាប់ការធ្វើដំណើរ និង ម្ហូបអាហារប្រចាំថ្ងៃឡើយ ។

រោងចក្រធ្វើកែវស្ថិតប្រហែលជិត ២០ គ.ម. ពីរាជធានីភ្នំពេញ ដូច្នេះខ្ញុំមិនអាចធ្វើដំណើរតាមទោចក្រយានដូចមុនឡើយ ។ ខ្ញុំត្រូវចំណាយប្រាក់ជិះរ៉ឺម៉កម៉ូតូទៅធ្វើការរៀងរាល់ថ្ងៃ ។ ម្យ៉ាងទៀត ដោយខ្ញុំត្រូវទៅធ្វើការនៅការិយាល័យ ខ្ញុំត្រូវស្លៀកពាក់ឲ្យបានស្អាតបាត ហើយត្រូវចូលទៅទទួលទានអាហារនៅភោជនីយដ្ឋានណាដែលសមរម្យ ដើម្បីឲ្យសមជាអ្នកធ្វើការនៅក្នុងការិយាល័យផង ។

រាល់ថ្ងៃ ខ្ញុំចេញតាំងពីព្រលឹមដើម្បីទៅធ្វើការឲ្យបានមុនម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៦ ល្ងាចទើបត្រឡប់មកផ្ទះវិញ ។ ខ្ញុំត្រូវធ្វើការនៅក្នុងបន្ទប់របស់លោកនាយគណនេយ្យករ ដែលជាបន្ទប់មួយដាច់ដោយឡែកពីបុគ្គលិកដទៃទៀត ។ ក៏ប៉ុន្តែនៅក្នុងបន្ទប់នោះ មានការិយាល័យរបស់លោកនាយ ការិយាល័យរបស់នាយរង និង ការិយាល័យរបស់មន្ត្រីទទួលបន្ទុកគិតគូរតម្លៃនៃផលិតផលផង ។

លោកនាយគណនេយ្យករ ជាសាស្ត្រចារ្យមួយរូប ដែលមានឈ្មោះល្បីនៅក្នុងមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ គាត់រស់នៅជាអភិជន ដែលទទួលការអប់រំនៅប្រទេសបារាំង ។ គាត់មានប្រពន្ធជាជនជាតិបារាំង ។ គាត់មកធ្វើការដោយមានអ្នកបើកបរពាក់ឯកសណ្ឋាន ។ នៅបាំងខាងក្រោយនៃរថយន្តម៉ាកដេអេស (DS) របស់បារាំង គាត់ដក់ខ្សៀយ៉ាងសង្ហារ ។ តាមធម្មតា លោកនាយមកធ្វើការនៅរោងចក្រកែវមួយអាទិត្យម្តង ពីព្រោះគាត់ធ្វើការនៅច្រើនកន្លែង ទាំងក្នុងក្រុមហ៊ុនរដ្ឋ ទាំងក្នុងក្រុមហ៊ុនឯកជន ជាប្រធានផ្នែកគណនេយ្យ ជាអ្នកត្រួតបញ្ជី ឬ ជាស្នងការគណនេយ្យ ។ល។ បន្ថែមលើមុខងារជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រផង នៅមហាវិទ្យាល័យនិតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចផង ។

ក្នុងការងាររបស់ពួកយើង ប្រសិនបើជាការចាំបាច់ យើងត្រូវទៅរកលោកនាយនៅផ្ទះរបស់គាត់ ដែលជាភូមិគ្រឹះមួយនៅតាមវិថីសហពន្ធរុស្ស៊ី ។ ឬបើរកគាត់

មិនឃើញ យើងអាចទៅរកលោកនាយ នៅកន្លែងធ្វើការដទៃទៀតរបស់គាត់ ដូចជានៅឯស្ថានីយរាជអយស្ម័យយានជាដើម ។ ខ្ញុំឮគេនិយាយតៗគ្នាថាធ្វើការជាមួយលោកនាយនេះ នឹងមានអនាគតល្អ ព្រោះអាចចេះដឹងការងារច្រើន ។ ក៏ប៉ុន្តែលោកនាយ មិនងាយឲ្យប្រាក់ខែច្រើនឡើយ ។

រោងចក្រធ្វើកែវ ក៏ដូចជារោងចក្ររដ្ឋមួយចំនួនធំទៀតដែរ សុទ្ធសឹងជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ។ នៅពេលខ្ញុំចូលធ្វើការនោះ គេឃើញមានទីប្រឹក្សាបច្ចេកទេសដែលជាជនជាតិចិនមួយចំនួននៅឡើយ ។ ក្នុងរយៈពេលមួយខែនៅក្នុងរោងចក្ររដ្ឋនេះ ខ្ញុំបានស្គាល់លោកនាយគណនេយ្យករច្បាស់ណាស់ តែខ្ញុំមិនដែលបានជួបមុខលោកប្រធានអគ្គនាយកដែលមានឋានៈជាឧត្តមមន្ត្រីគឺ លោក ទេព ថន ម្តងណាឡើយ ។ នៅពេលខ្ញុំដាក់ពាក្យសុំឈប់ពីការងារ លោកនាយនិយាយជាភាសាបារាំងមករកខ្ញុំថា៖ "លោកច្បាស់ជាចង់ឈប់ពីការងារមែនឬ?" គាត់បន្ថែមថា "មែន ខ្ញុំមិនអាចឲ្យប្រាក់ខែលើសពីនេះទេក្នុងពេលនេះ" ។ ខ្ញុំឆ្លើយថាប្រាក់ខែរបស់ខ្ញុំមានចំនួនមិនគ្រប់គ្រាន់សំរាប់ការរស់នៅៗភ្នំពេញឡើយ ។ តាមការពិត ខ្ញុំមិនប៉ងប្រាថ្នាទារយកប្រាក់ខែខ្ពស់អ្វីនោះទេ តែប្រាក់ខែ ៤០ ដុល្លារ ពិតជាមិនគ្រប់គ្រាន់សំរាប់តម្លៃជីវភាពនៅសម័យនោះសោះឡើយ ។ ដូច្នេះ នៅអាយុជិត ១៨ ឆ្នាំ ខ្ញុំក៏លាឈប់ពីការងារនៅរោងចក្ររដ្ឋធ្វើកែវនោះទៅ ។ នៅអាយុ ១៨ ឆ្នាំនេះ ខ្ញុំនឹកថាខ្ញុំប្រហែលជានៅក្មេងមែន តែខ្ញុំជឿថាខ្ញុំបានទទួលការហ្វឹកហាត់ក្នុងការងារបានល្អហើយ ។ ការងារនៅក្នុងរោងចក្ររដ្ឋធ្វើកែវ ជាបទពិសោធន៍ដ៏វិសេសវិសាលមួយសំរាប់ខ្ញុំក្នុងពិភពកម្មកររោងចក្រ ។

# បានការធ្វើនៅក្នុងក្រុមហ៊ុនសុរាគារខ្មែរ

នៅទីបំផុត ខ្ញុំត្រូវពឹងពាក់ កន្និដ្ឋា ដើម្បីឲ្យជួយរកការងារធ្វើនៅក្នុងក្រុមហ៊ុនសុរាគារខ្មែរ ។ ដោយសារគុណបុណ្យរបស់កន្និដ្ឋា ខ្ញុំក៏បានទទួលការធ្វើជាលេខាធិការគណនេយ្យ នៅក្រោមអំណាចរបស់គូដណ្តឹងរបស់នាង ។ ក៏ប៉ុន្តែ ខ្ញុំត្រូវទៅធ្វើការនៅឯរោងចក្រសុរាគារខ្មែរឯគីឡូលេខ ៦ គឺ មិនធ្វើការជាមួយមិត្តភក្តិឯទៀត នៅទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនឡើយ ។ ខ្ញុំត្រូវធ្វើការនៅខាងផ្នែកវាយតម្លៃនៃផលិតផលស្រាបៀរជាមួយនឹងបុគ្គលិកមួយចំនួន ដែលសុទ្ធតែជាអតីតនិស្សិតចេញពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ ក្នុងមុខងារថ្មីនេះ ខ្ញុំត្រូវបានទទួលប្រាក់ខែលើសពីរដង បើប្រៀបធៀបនឹងប្រាក់ខែនៅរោងចក្រធ្វើកែវ ។

ព្រឹកៗ រាល់ថ្ងៃធ្វើការ ខ្ញុំជិះរថយន្តកង់បី ហៅថា ឡាំប្រឺតា (Lambretta) ពីផ្សារដើមគ ទៅឈប់នៅផ្សារថ្មី រួចទៅជិះរថយន្តកង់បីមួយទៀត ពីផ្សារថ្មីទៅគីឡូលេខ ៦ ។ សម័យនោះ យើងធ្វើការពីរពេលគឺ នៅពេលព្រឹកពីម៉ោង ៧ ដល់ម៉ោង ១២ ថ្ងៃត្រង់ និង ពីម៉ោង ២ រសៀល ដល់ម៉ោង ៥ ល្ងាច ។ តាមធម្មតា ពេលមកដល់ផ្សារធំថ្មី មុននឹងឡើងរថយន្ត បន្តដំណើរត្រឡប់មកផ្សារដើមគ ដើម្បីសម្រាកខ្ញុំតែងទិញសាច់ចំអិនស្រាប់ សាច់កាត់ជាកំណាត់ៗដុំៗ មាន គ្រឿងក្នុង បេះដូង ឬពោះវៀនតាន់ជាដើម ដែលចិនដាក់លើគ្រែចល័ត ដើរលក់ តាមចំណតរថកង់បី ។ ខ្ញុំពមសាច់ពីរ ឬ បីម៉ាត់នៅពេលរង់ចាំ មុននឹងឡើងជិះឡាំប្រឺតាមកទទួលទានអាហារថ្ងៃត្រង់ឯផ្ទះ ។ ក្រោយពីធ្វើការនៅគីឡូលេខ ៦ បានប៉ុន្មានខែ ខ្ញុំក៏ត្រូវផ្លាស់មកធ្វើការនៅក្នុងរាជធានីវិញ ។

# ខ្ញុំបេះតែចង់រៀនបន្ត

ទោះជាខ្ញុំជាប់រវល់ក្នុងការងារក្តី ខ្ញុំក៏តែងតែចិញ្ចឹមចិត្តទុកជានិច្ចថានឹងបន្តការសិក្សាឲ្យបានខ្ពស់តទៅទៀត ។ ដូច្នេះ ខ្ញុំក៏ឆ្លៀតឱកាសទៅចុះឈ្មោះរៀននៅសាលាឯកជនឈ្មោះហៅថា "វិជ្ជាស្ថានពាណិជ្ជកម្ម" (Institut Commercial) ស្ថិតនៅក្បែរផ្សារធំថ្មី នៅជាប់ជាមួយវិទ្យាល័យឯកជនឈ្មោះ វ៉ុលទែរ (Lycée Voltaire) ។ នៅឆ្នាំ ១៩៧០ ខ្ញុំក៏ចូលប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងគណនេយ្យដែលរៀបចំឡើងដោយមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។ វិញ្ញាសាប្រឡងមានវិញ្ញាសាសរសេរ និង វិញ្ញាសាផ្ទាល់មាត់ ។ នៅពេលដែលខ្ញុំចូលទៅក្នុងបន្ទប់ ដែលត្រូវចូលម្នាក់ម្តងៗ ដើម្បីទៅធ្វើវិញ្ញាសាផ្ទាល់មាត់ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងព្រោះលោកមេប្រយោគដែលអង្គុយរង់ចាំសួរដេញដោលខ្ញុំនោះ គ្មាននរណាក្រៅពីលោកនាយគណនេយ្យករចាស់របស់ខ្ញុំ កាលខ្ញុំធ្វើការនៅរោងចក្ររដ្ឋធ្វើកែវនោះទេ ។ លោកមេប្រយោគនោះឈ្មោះលោក អ៊ឹង ភូរិន ។ នៅពេលដែលខ្ញុំចូលអង្គុយទល់មុខគាត់ៗញញឹមហើយសួរមកខ្ញុំថា៖ "លោកឈ្មោះ អៀង មូលលី មែនទេ?" ខ្ញុំឆ្លើយយ៉ាងរហ័សថា៖ "បាទទាន" ។ បន្ទាប់មក លោកមេប្រយោគឲ្យខ្ញុំលូកដៃទៅក្នុងប្រអប់មួយ ដើម្បីចាប់យកក្រដាស់បត់ផ្នត់យ៉ាងត្រឹមត្រូវមួយសន្លឹកក្នុងចំណោមក្រដាស់ផ្នត់ជាច្រើន ដែលមានសរសេរជាសំណួរ ដែលខ្ញុំត្រូវឆ្លើយដោយផ្ទាល់មាត់ ។ ខ្ញុំក៏ប្រឡងជាប់វិញ្ញាបនរដ្ឋគណនេយ្យថ្នាក់ជាន់ខ្ពស់ ដែលជាសញ្ញាប័ត្រផ្នែកគណនេយ្យថ្នាក់ខ្ពស់ជាងគេ នៅប្រទេសកម្ពុជាយើងនៅឆ្នាំ ១៩៧០ ។

# ខ្ញុំចេះតែចង់រៀនបន្តនៅប្រទេសបារាំង

ដោយសារទទួលបាននូវសញ្ញាប័ត្រនេះ ខ្ញុំក៏មានចិត្តចង់បន្តទៅសិក្សានៅប្រទេសបារាំងថែមទៀត ។ ចិត្តដែលចេះតែចង់ទៅរៀននៅប្រទេសបារាំង ក៏ព្រោះតែយល់ឃើញថា ឲ្យតែមានសញ្ញាប័ត្រណាមួយមកពីប្រទេសបារាំង សញ្ញាប័ត្រនោះតែងតែមានតម្លៃជាងសញ្ញាប័ត្រក្នុងស្រុកជានិច្ច ។ ក៏ប៉ុន្តែ គំនិតនោះក៏ចាប់ផ្តើមជួបប្រទះនឹងឧបសគ្គបណ្តើរៗទៅហើយ ព្រោះនៅពេលនោះ ប្រទេសកម្ពុជាយើង ចាប់ផ្តើមធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាមកើតឡើងដោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ។ ខ្ញុំគ្មានសង្ឃឹមថានឹងអាចចាកចេញទៅក្រៅប្រទេសបានទេ នៅសម័យស្រុកកើតសង្គ្រាមនោះ ។ ក៏ប៉ុន្តែ ខ្ញុំក៏ខិតខំរិះរកវិធីផ្សេងដើម្បីអាចប្រឡងយកសញ្ញាប័ត្រពីប្រទេសបារាំង ។ វិធីមួយនោះគឺ ធ្វើការសិក្សាតាមលិខិតឆ្លើយឆ្លង (Distant Learning) ។ ខ្ញុំចាប់ផ្តើមសរសេរលិខិត ទៅស្ថាប័នសិក្សាជាច្រើននៅប្រទេសបារាំង ។ ចម្លើយត្រឡប់មកវិញមានដដែលៗគឺ គេឲ្យខ្ញុំសុំការទទួលស្គាល់ពីប្រទេសបារាំងជាមុនថាតើសញ្ញាប័ត្រដែលខ្ញុំមាននោះ មានតម្លៃស្មើនឹងសញ្ញាប័ត្របារាំងត្រឹមកំរិតណា? បើគេដឹងថាអាចត្រឹមកំរិតណាហើយ ទើបគេអាចឲ្យខ្ញុំចូលរៀន ឬ ត្រៀមប្រឡងពីចម្ងាយ ដើម្បីឈានទៅយកសញ្ញាប័ត្របារាំងណាមួយ ។ ខ្ញុំគិតថាការទទួលស្គាល់សញ្ញាប័ត្រ ជាភារកិច្ចរបស់ក្រសួងមានសមត្ថកិច្ចបារាំង និង ខ្មែរគឺមិនមែនជាភារកិច្ចរបស់ឯកជនណាមួយដែលអាចធ្វើបានឡើយ ។ ដូច្នេះ ខ្ញុំក៏ព្យាយាមធ្វើការទាក់ទងជាមួយមន្ត្រីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដើម្បីស្វែងរកការទទួលស្គាល់នោះ ។ ក៏ប៉ុន្តែ នៅពេលនោះ គ្មាននរណាអាចផ្តល់ព័ត៌មានដល់ខ្ញុំបានច្បាស់លាស់ឡើយ ។ អស់រយៈពេលជាច្រើនខែ ដោយគ្មានបានផលអ្វីជាក់ស្តែងនោះ ខ្ញុំក៏ដាច់ចិត្តសរសេរលិខិតជាភាសាបារាំងមួយច្បាប់ ចុះថ្ងៃទី

២២ ខែមករា ឆ្នាំ ១៩៧១ ទៅក្រសួងសិក្សាធិការនៅទីក្រុងប៉ារីស ដោយពន្យល់ពីគោលបំណងរបស់ខ្ញុំ និង មុខវិជ្ជាទាំងឡាយដែលខ្ញុំបានរៀនចប់នៅក្នុងប្រទេសកម្ពុជា ។ ខ្ញុំមានបំណងចង់ឈោងយកមុខរបរជាអ្នកជំនាញគណនេយ្យ (Expert Comptable) បន្ទាប់ពីបានការអនុញ្ញាតឲ្យចុះឈ្មោះរៀនក្នុងគ្រឹះស្ថានសិក្សារបស់បារាំងណាមួយ ។ ខ្ញុំនឹកថា ខ្ញុំនឹងរៀនតាមលិខិតឆ្លើយឆ្លងផង ធ្វើការនៅក្នុងប្រទេសកម្ពុជាផង ។ ក៏ប៉ុន្តែ ពីមួយខែទៅមួយខែ ខ្ញុំតែងទន្ទឹងរង់ចាំចម្លើយពីប្រទេសបារាំង ដែលបាត់ឈឹងពុំឃើញឆ្លើយតបមកខ្ញុំវិញសោះ ។ សេចក្តីសង្ឃឹមរបស់ខ្ញុំក្នុងការបន្តវិជ្ជាតាមលិខិតឆ្លើយឆ្លងនោះ ក៏រលាយបាត់បន្តិចម្តងៗរហូតដល់អស់សង្ឃឹមសូន្យតែម្តង ។

## ខ្ញុំចង់ធ្វើជាគណនេយ្យករឯករាជ្យ

នៅពេលជាមួយគ្នានោះ ខ្ញុំក៏មានគំនិតចង់ប្រកបរបរជាគណនេយ្យករឯករាជ្យ ដែលអាចបើកការិយាល័យបំរើសេវាគណនេយ្យដល់ក្រុមហ៊ុនពាណិជ្ជកម្ម ឬ ក្រុមហ៊ុនឧស្សាហកម្មដោយខ្លួនឯង ។ នៅសម័យនោះ ប្រទេសយើងពុំទាន់មានច្បាប់ ឬ ក្បួនខ្នាតទាក់ទងនឹងលក្ខន្តិកៈនៃគណនេយ្យករឯករាជ្យច្បាស់លាស់នៅឡើយទេ ។ តាមខ្ញុំដឹងថាក្នុងពេលកន្លងមក មានគណនេយ្យករដែលមានបទពិសោធន៍ ជាពិសេសជនជាតិវៀតណាមមួយចំនួន បានទៅចុះឈ្មោះ ទទួលបាននូវការទទួលស្គាល់ពីតុលាការពាណិជ្ជកម្មនៅរាជធានីភ្នំពេញ ។ កាលណាមានចុះឈ្មោះក្នុងបញ្ជី ដែលទទួលស្គាល់ដោយតុលាការហើយ គណនេយ្យករនោះអាចប្រកបអាជីវកម្មជាគណនេយ្យករឯករាជ្យដោយសេរី ។ ដូច្នេះបានជានៅឆ្នាំ ១៩៧១ ខ្ញុំក៏បានធ្វើពាក្យទៅសុំចុះបញ្ជីការនៅតុលាការពាណិជ្ជកម្មក្រុងភ្នំពេញ ។ ក៏ប៉ុន្តែ កាលនោះប្រហែលជាលោកចាងហ្វាង ដែលជាចៅក្រមទទួលខុសត្រូវយល់

ថាខ្ញុំនៅក្មេងពេក ទើបគាត់ឆ្លើយប្រាប់ខ្ញុំថាគាត់មិនដែលដឹងឮពីរបៀបរបបនៃការចុះឈ្មោះគណនេយ្យករណាមួយ នៅក្រោមអំណាចសាលារបស់គាត់ឡើយ ។ ដូច្នេះ បំណងរបស់ខ្ញុំដែលចង់ប្រកបរបរជាគណនេយ្យករឯករាជ្យ ក៏រលាយបាត់ទៀតដែរ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅខំព្យាយាម ដើម្បីឈានឲ្យបានទៅដល់ទីដៅដែលខ្ញុំបានកំណត់រួចហើយនោះ ។ ខ្ញុំចាប់ផ្តើមធ្វើការស្រាវជ្រាវរាវរកសមាគមវិជ្ជាជីវៈខាងផ្នែកគណនេយ្យនៅប្រទេសបារាំង ដើម្បីសុំឲ្យគេជួយណែនាំ ។

ខ្ញុំរកឃើញអាស័យដ្ឋានពីរនៅទីក្រុងប៉ារីស ។ ខ្ញុំសរសេរសំបុត្រទៅសមាគមគណនេយ្យមួយឈ្មោះ Société de Comptabilité de France (SCF) ឬ អេស.សេ.អេហ្វ ដោយរៀបរាប់អំពីសកម្មភាពការងារបទពិសោធន៍ និង ការរៀនសូត្ររបស់ខ្ញុំហើយខ្ញុំស្នើសុំចូលជាសមាជិកក្នុងឋានៈវិជ្ជាជីវៈណាមួយនៃសមាគមនោះ ។

តាមពិត ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ខ្ញុំក៏មានការរីកចំរើនខ្លះដែរក្នុងមុខរបរវិជ្ជាជីវៈរបស់ខ្ញុំគឺ ខ្ញុំមិនមែនស្ថិតនៅជាន់ទាបទៀតឡើយ ។ រយៈពេលបីខែក្រោយដែលខ្ញុំចូលធ្វើការនៅក្រុមហ៊ុនសុរាគារខ្មែរ ក្នុងឋានៈជាជំនួយគណនេយ្យករ ខ្ញុំត្រូវបានឡើងឋានៈជាគណនេយ្យករពេញសិទ្ធិ ។ នៅឆ្នាំ ១៩៧១ ខ្ញុំក៏ចេញពីក្រុមហ៊ុនសុរាគារខ្មែរ ទៅធ្វើការនៅក្នុងក្រុមហ៊ុនស្តង់ឌីណាវមួយ ជាទីដែលខ្ញុំបានទទួលប្រាក់ខែកើនឡើងបីដង បើប្រៀបធៀបទៅនឹងប្រាក់ខែរបស់ខ្ញុំនៅក្រុមហ៊ុនសុរាគារខ្មែរ (SKD) ។ ជាមួយគ្នានោះ តាមលិខិតចុះថ្ងៃទី ២៤ ខែសីហា ១៩៧១ សមាគមគណនេយ្យ អេស.សេ.អេហ្វ បានផ្តល់ដំណឹងដល់ខ្ញុំថាគណៈកម្មាធិការនាយករបស់សមាគម បានផ្តល់ឋានៈដល់ខ្ញុំជាសមាជិកគណនេយ្យករគុណវុឌ្ឍី (Membre Comptable Qualifié) ។ ឋានៈវិជ្ជាជីវៈនេះមានសារសំខាន់ខ្លាំងណាស់ចំពោះខ្ញុំ ក៏ប៉ុន្តែ នៅពេលភ្លាមៗនោះ ខ្ញុំហាក់ដូចជាមិនសូវយក

ចិត្តទុកដាក់ប៉ុន្មានឡើយ ។ ដោយសារឋានៈវិជ្ជាជីវៈនេះ ខ្ញុំក៏កើតមានចិត្តចង់ទៅរៀននៅប្រទេសបារាំងសារជាថ្មីម្តងទៀត ។

ចំពោះលិខិតដែលខ្ញុំសរសេរ ទៅក្រសួងសិក្សាធិការរបស់ប្រទេសបារាំង ដើម្បីសុំការទទួលស្គាល់សញ្ញាប័ត្ររបស់ខ្ញុំនោះ ក្រសួងនេះ បានឆ្លើយភ្លាមៗមកខ្ញុំវិញនៅខែ កុម្ភៈ ឆ្នាំ ១៩៧១ ដែរ ។ តាមពិត ខ្ញុំត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះរៀននៅវិជ្ជាស្ថានជាតិបច្ចេកទេសគណនេយ្យ និង សេដ្ឋកិច្ច (Institut National des Techniques Economiques et Comptables) នៅទីក្រុងប៉ារីស ។ ក៏ប៉ុន្តែ លិខិតនោះបានត្រូវផ្ញើទៅអាស័យដ្ឋានរបស់ខ្ញុំ នៅទីកន្លែងធ្វើការ ឯក្រុមហ៊ុនសុរាគារខ្មែរឯនោះ នៅពេលដែលខ្ញុំចេញទៅធ្វើការនៅកន្លែងផ្សេងទៀតទៅហើយនោះ ។ នៅពេលសំបុត្រនោះទៅដល់ក្រុមហ៊ុនសុរាគារខ្មែរ លោកនាយផ្នែកបុគ្គលិកក៏ទុកចោលនៅលើការិយាល័យរបស់គាត់យ៉ាងព្រងើយ ដោយមិនបានអើពើផ្ញើបន្តមកខ្ញុំឡើយ ។

ដោយពុំបានដឹងថា ក្រសួងសិក្សាធិការបារាំង បានផ្ញើចម្លើយមកខ្ញុំរួចហើយនៅខែ កុម្ភៈ ឆ្នាំ ១៩៧១ នោះ នៅដើមឆ្នាំ ១៩៧២ ខ្ញុំក៏សរសេរសុំទៅអាជ្ញាធរបារាំងម្តងទៀត ឲ្យទទួលស្គាល់សញ្ញាប័ត្ររបស់សាលាសារជាថ្មី ។ កាលនោះ ខ្ញុំចូលចិត្តសរសេរសំបុត្រឆ្លើយឆ្លងទៅក្រៅប្រទេសណាស់ ។ លើកនេះក្រសួងសិក្សាធិការបារាំង បានតម្រូវឲ្យខ្ញុំផ្តល់ដល់អាជ្ញាធរបារាំងនូវឯកសារផ្លូវការណាមួយដែលមានចែងលំអិតអំពីកម្មវិធីសិក្សារបស់ខ្ញុំ ។ ដូច្នេះ ខ្ញុំក៏ត្រូវធ្វើការទាក់ទងជាថ្មីជាមួយមន្ត្រីនៃមហាវិទ្យាល័យពាណិជ្ជសាស្រ្ត ដើម្បីរកឯកសារផ្លូវការស្តីពីកម្មវិធីសិក្សានោះ ។ ក៏ប៉ុន្តែ គ្មានមន្ត្រីណាម្នាក់អាចផ្តល់ឯកសារនោះដល់ខ្ញុំបានឡើយ ។

នៅទីបំផុត ខ្ញុំក៏ដោះស្រាយបញ្ហានេះ ដោយរៀបរៀងកម្មវិធីសិក្សានោះដោយខ្លួនឯង ។ ខ្ញុំចម្លងមុខវិជ្ជាលំអិតទាំងឡាយដែលខ្ញុំបានរៀន ។ ខ្ញុំវាយអង្គុលី

លេខខ្លួនឯង រួចខ្ញុំសុំឲ្យកម្មករនៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រជួយយកទៅវាយត្រាផ្លូវការរបស់មហាវិទ្យាល័យដើម្បីឲ្យមានលក្ខណៈត្រឹមត្រូវ ។ ខ្ញុំផ្ញើឯកសារនោះទៅប្រទេសបារាំង ។ នៅចុងឆ្នាំ ១៩៧២ ខ្ញុំបានទទួលចម្លើយម្ដងទៀតថា ខ្ញុំមានសិទ្ធិត្រៀមប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងវិជ្ជាគណនេយ្យ នៅប្រទេសបារាំងបាន ។ លើកនេះ ចំពោះខ្ញុំ សេចក្ដីសង្ឃឹមកើតមានឡើងវិញហើយ ។ ខ្ញុំក៏ចាប់ស្រមៃម្ដងទៀតថា នឹងទៅទាញយកមុខរបរជាអ្នកជំនាញការខាងផ្នែកគណនេយ្យឲ្យបាន ។ មួយសប្ដាហ៍បន្ទាប់ពីបានចម្លើយពីប្រទេសបារាំងមក ខ្ញុំក៏ឆ្លៀតទៅលេងមិត្តភក្តិរបស់ខ្ញុំ នៅក្រុមហ៊ុនសុរាគារខ្មែរ ។ នៅពេលខ្ញុំទើបតែដើរចូលទៅក្នុងការិយាល័យរដ្ឋបាលនៃក្រុមហ៊ុន លោកនាយផ្នែកបុគ្គលិកសម្ដែងអាកប្បកិរិយារាប់អានដ៏ចម្លែកមករកខ្ញុំ ដោយហៅឲ្យចូលមកអង្គុយលេងនៅក្នុងការិយាល័យរបស់គាត់ ។ នៅពេលនោះ លោកនាយបានរើគំនរឯកសារមួយចំនួនរួចហូតយកសំបុត្រមួយច្បាប់ ដែលនៅខាងក្រោមបង្អស់មកហុចឲ្យខ្ញុំ ។ ខ្ញុំពិនិត្យលិខិតនោះ ទើបយល់ថាជាលិខិតដែលក្រសួងសិក្សាធិការបារាំងបានផ្ញើមកខ្ញុំ តាំងពីខែ កុម្ភៈ ឆ្នាំ ១៩៧១ មកម្ល៉េះ ។ ខ្ញុំនឹកហួសចិត្ត ដោយសារការយឺតយ៉ាវនេះ ។ ប្រសិនបើខ្ញុំដឹងថា បារាំងបានឆ្លើយមកកាលពីជាងមួយឆ្នាំមុននោះ ម្ល៉េះខ្ញុំមិនខាតពេលវេលារង់ចាំចម្លើយ និង មានការលំបាកក្នុងការតាក់តែងកម្មវិធីសិក្សាអ្វីឡើយ ។ លោកនាយហាក់ពុំមានយកចិត្តទុកដាក់ចំពោះក្ដីមួរហ្មងរបស់ខ្ញុំទេ ។ គាត់រក្សាឥរិយាបថយ៉ាងរំភើយ ដោយពុំបានគិតថាទង្វើរបស់គាត់ធ្វើឲ្យខ្ញុំខាតពេលវេលាដ៏មានតំលៃយ៉ាងសន្ធឹកសន្ធាប់របស់ខ្ញុំសោះឡើយ ។

# ស្ថានការណ៍ប្រែប្រួល

ចាប់តាំងពីខ្ញុំចេញធ្វើការមក មានព្រឹត្តិការណ៍សំខាន់ៗបានកើតឡើងក្នុងរង្វង់គ្រួសាររបស់យើង ។ បងប្រុសទីមួយរបស់ខ្ញុំ បានចេញទៅបង្រៀននៅកំពង់ស្រឡៅ ក្នុងខេត្រព្រះវិហារ ក្បែរទល់ដែនប្រទេសលាវ ។ យូរៗម្តង គាត់មកលេងពួកយើងនៅភ្នំពេញ ដោយយកមកជាមួយនូវផលិតផលរត់ពន្ធមួយចំនួនដូចជា ស្រា Cognac ឬ ទឹកអប់បារាំងជាដើម ។ នៅសម័យនោះ ទឹកអប់ម៉ាកសំប៉ាញ (Champagne) កំពុងពេញនិយមណាស់ដែរ ។ នៅឆ្នាំ ១៩៧០ បងប្រុសខ្ញុំត្រូវផ្លាស់មកបង្រៀននៅខេត្រកណ្តាលជិតរាជធានីភ្នំពេញវិញ ។ បងប្រុសទីពីររបស់ខ្ញុំ បានការងារធ្វើនៅធនាគារជាតិនៃកម្ពុជា នៅពេលដែលគាត់បន្តការសិក្សានៅមហាវិទ្យាល័យនិតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។

ផ្ទះឈើដ៏តូចរបស់យើង ត្រូវបានជួសជុលកែលំអឡើង ដោយបានត្រូវលើកឡើងឲ្យខ្ពស់ថែមទៀត និង រៀបឥដ្ឋចាក់ស៊ីម៉ង់ត៍ខាងក្រោម រៀបបន្ទប់លាបពណ៌យ៉ាងស្អាតបាត រៀបចំប្រព័ន្ធអគ្គិសនី និង ប្រព័ន្ធទឹកស្អាតយ៉ាងទំនើប ។ ក៏ប៉ុន្តែ ចាប់ពីត្រីមាសទី ៣ នៃឆ្នាំ ១៩៧០ ផលវិបាកនៃសង្គ្រាមចាប់ផ្តើមគាបសង្កត់មកលើជីវភាពរបស់យើងម្នាក់ៗកាន់តែខ្លាំងឡើងៗជាលំដាប់ ។ ប្រទេសយើងត្រូវចែកជាតំបន់ពីរផ្សេងគ្នា មួយជាតំបន់ព្រៃម៉ាគី និង តំបន់មួយទៀតជាតំបន់ដែលស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាល លន់ នល់ ។

នៅភូមិស្នាយពល មន្ត្រីរាជការសំខាន់ៗ ទាំងប៉ូលីស ទាំងស៊ីវិល ភាគច្រើនបានភៀសខ្លួនចេញមករស់នៅៗទីក្រុងភ្នំពេញ ។ ម្តាយខ្ញុំ និង ប្អូនតូចៗមាន វន្នី វុធឿន វុធឿន វុទ្ធា និង សោភា បានមករស់នៅជាមួយពួកយើង ឯរាជធានីតាំងពីខែ មេសា ឆ្នាំ ១៩៧០ មកម្លេះ ។ ចំណែកឪពុកខ្ញុំ ប្អូនខ្ញុំមាន ស៊ីថាន វណ្ណៈ

និង ណារីន មិនទាន់បានមករស់នៅជាមួយយើងនៅឡើយទេ អ្នកទាំងនោះបន្តរស់នៅក្នុងភូមិស្នាយពលអស់មួយរយៈទៀត ។ យើងបែកគ្នាជាពីរក្រុម មួយក្រុមមករស់នៅក្នុងក្រុងភ្នំពេញ មួយក្រុមទៀតរស់នៅៗក្នុងភូមិស្នាយពលជាបណ្តោះអាសន្នសិន ។ ក៏ប៉ុន្តែ ក្រោយពីម្តាយខ្ញុំចេញពីភូមិស្នាយពលមិនយូរប៉ុន្មានមានយុទ្ធជន ក្នុងសំលៀកបំពាក់ខ្មៅមួយក្រុម បានជិះម៉ូតូចូលមកក្នុងភូមិ ហើយរៀបចំជាគណៈកម្មាធិការបដិវត្តន៍ប្រជាជនគ្រប់គ្រងស្រុកពារាំងទាំងមូល ។ ខ្ញុំឮគេនិយាយថា យុទ្ធជនដែលមកមុនគេនោះគឺ ពួកកុម្មុយនីស្តសញ្ជាតិវៀតណាម ។ គណៈកម្មាធិការស្រុកនេះ ក៏រៀបចំគណៈកម្មាធិការឃុំ និង ភូមិជាបន្តបន្ទាប់នាពេលក្រោយៗមកទៀត ។

ខ្ញុំមានឪពុកមាពីររូប ដែលជាប្អូនបង្កើតរបស់ម្តាយខ្ញុំ ។ ឪពុកមាម្នាក់ដែលជាប្អូនពៅបានត្រូវជ្រើសរើសឲ្យកាន់តំណែងជាប្រធានគណៈកម្មាធិការស្រុក ដែលមានអំណាចស្មើនឹងអភិបាលស្រុកយ៉ាងនោះដែរ ។ កាលក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ គាត់ជាអ្នកបច្ចេកទេសម្នាក់ ធ្វើការនៅរោងចក្រវាយនភ័ណ្ឌ នៅខែត្រកំពង់ចាម ។ គាត់ត្រូវបានរបបសង្គមរាស្ត្រនិយមរបស់សម្តេច សីហនុ ចោទប្រកាន់ថាជាពួកខ្មែរក្រហម ហើយត្រូវជាប់ឃុំឃាំងនៅពន្ធនាគារព្រៃស អស់រយៈពេលជាច្រើនឆ្នាំ ។ តាមពិតឪពុកមាខ្ញុំ មិនមែនជាជនកុម្មុយនីស្តអ្វីទេ គាត់គ្រាន់តែមានទំនាក់ទំនងជិតស្និទ្ធជាមួយបញ្ញវ័ន្ត ដែលមាននិន្នាការសង្គមនិយមមួយចំនួន ដូចជាលោក ភោគ ឆាយ ជាដើមតែប៉ុណ្ណោះ ។ ប៉ុន្មានខែមុនពេលលោក លន់ នល់ ទម្លាក់សម្តេចពីអំណាច រដ្ឋាភិបាល លន់ នល់ បានដោះលែងអ្នកទោសនយោបាយទាំងអស់ពីពន្ធនាគារព្រៃស ដើម្បីអូសទាញឲ្យអ្នកទាំងនោះគាំទ្ររបបថ្មី ដែលនឹងកើតឡើងក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ។ ឪពុកមាខ្ញុំ ក៏ស្ថិតនៅក្នុងចំណោមអ្នកទទួលការលើកលែងទោសពីលោក លន់ នល់ ដែរ ។ ក៏ប៉ុន្តែ ហាក់ដូចជាការ

ចំអកនៃព្រហ្មលិខិត អ្នកទោសដែលត្រូវលោក លន់ នល់ ដោះលែងទាំងនោះ មិនបានគាំទ្ររបបរបស់គាត់ទាំងអស់ទេ ភាគច្រើនអ្នកទាំងនោះ បានរត់ចូលព្រៃម៉ាគី (Maquis)[25] ទៅបំរើចលនាតស៊ូ តាមការស្រែកអំពាវនាវរបស់សម្តេច សីហនុ ប្រឆាំងតទល់នឹងរបប លន់ នល់ ទៅវិញ ។ នៅពេលទទួលសេរីភាពភ្លាម ឪពុកមាខ្ញុំស្នាក់នៅក្នុងក្រុងភ្នំពេញតែរយៈពេលមួយយ៉ាងខ្លីតែប៉ុណ្ណោះ ។ គាត់ត្រឡប់មករស់នៅ ក្នុងភូមិកំណើត ឯភូមិស្នាយពល រហូតដល់ពេលដែលគាត់ត្រូវទទួលការជ្រើសតាំងជាគណៈកម្មាធិការស្រុកពារាំង ។ ភូមិស្នាយពល ក៏ក្លាយជាតំបន់ម៉ាគីមួយដ៏រឹងមាំ នៅទិសបូព៌ានៃប្រទេសកម្ពុជា សម្រាប់ពួកខ្មែរក្រហម ។

ក្រោយពីពេលដែល "រដ្ឋអំណាចបដិវត្តន៍ថ្មី" ត្រូវបានរៀបចំឡើងនៅក្នុងភូមិ យើងក៏ដាច់ការទាក់ទងគ្នាទាំងស្រុង ដោយសារពួកខ្មែរក្រហមធ្វើការហាមប្រាមមិនឲ្យអ្នកស្រុកទាក់ទងជាមួយតំបន់ខ្មាំងទៀតឡើយ ដែលក្នុងនោះមានរួមទាំងរាជធានីភ្នំពេញផង ។ ដូច្នេះ គ្រួសារខ្ញុំត្រូវកាត់ផ្តាច់ពាក់កណ្តាលឲ្យរស់នៅបែកគ្នា មួយផ្នែកនៅស្នាយពល មួយផ្នែកនៅភ្នំពេញ ។ យើងរងទុក្ខវេទនា ដោយសារការបែកខ្ញែកគ្នានេះយ៉ាងខ្លាំង ។ ឪពុកខ្ញុំ និយាយប្រាប់ខ្ញុំថាក្នុងរយៈជិតមួយឆ្នាំនៃការរស់នៅបែកគ្នានេះ គាត់ព្យាយាមលួចរត់មកភ្នំពេញជាច្រើនដងដែរ ។ នៅពេលមួយនោះ គាត់បានគេចផុតពីការត្រួតពិនិត្យរបស់ក្រុមខ្មែរក្រហម នៅស្រុកពារាំង តែគាត់ត្រូវបានក្រុមខ្មែរក្រហមនៅស្រុកជិតខាងគឺ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចាប់បានហើយឃុំឃាំងគាត់អស់រយៈពេលមួយថ្ងៃមួយយប់ ។

---

[25] The Maquis were rural guerrilla bands of French Resistance fighters, called *maquisards*, during the Occupation of France in World War II. Initially, they were composed of men who had escaped into the mountains to avoid conscription into Vichy France's Service du travail obligatoire (STO) to provide forced labor for Germany. To avert capture and deportation to Germany and remain free, they became increasingly organized in active resistance groups. ម៉ាគីមកពីភាសាបារាំង និយាយអំពីក្រុមអ្នកតស៊ូបារាំងប្រឆាំងកងទ័ពអាឡឺម៉ង់ នាសម័យសង្គ្រាមលោកលើកទី២ ដែលនាំគ្នាលាក់ខ្លួនតាមព្រៃភ្នំ ដើម្បីគេចចេញពីការចាប់បង្ខំឲ្យធ្វើទាហាន ឬ ចាប់បញ្ជូនទៅជំរុំប្រមូលផ្តុំនៃកងទ័ពអាឡឺម៉ង់ ។ ការលាក់ខ្លួននោះ ហៅថាចូលព្រៃម៉ាគី ដើម្បីធ្វើការតស៊ូប្រឆាំងអំណាចណាមួយ ។

ដោយមិនទាន់អាចសំរេចបំណងក្នុងការលួចចេញពីតំបន់ខ្មែរក្រហម ដើម្បីមករស់នៅជុំគ្នានៅទីក្រុងភ្នំពេញបាននោះ និង ប្រហែលជាក្នុងបំណងឲ្យថ្នាក់ដឹកនាំខ្មែរក្រហមជឿទុកចិត្តថាគាត់មិនវេសគេចចេញ ពីតំបន់របស់ពួកគេកាន់កាប់នោះទេ ទើបឳពុកខ្ញុំសំរេចរៀបការប្អូនស្រីខ្ញុំ ស៊ីថាន ជាមួយគ្រូបង្រៀនម្នាក់ នៅពេលដែលនាងមានអាយុប្រហែល ១៦ ឆ្នាំ ។ ពិធីរៀបអាពាហ៍ពិពាហ៍ប្អូនស្រីខ្ញុំបានប្រព្រឹត្តទៅដោយពុំមានការចូលរួមពីក្រុមគ្រួសារយើង ដែលស្ថិតនៅឯក្រុងភ្នំពេញទេ ។ កាលសម័យនោះ ពួកខ្មែរក្រហមនៅត្រូវការការគាំទ្រពីប្រជាពលរដ្ឋនៅឡើយ ។ ពួកគេ នៅមិនទាន់តឹងតែងណាស់ណាទេ ក្នុងការគ្រប់គ្រងប្រជាពលរដ្ឋដែលរស់នៅក្រោមអំណាចរបស់ខ្លួន ។ ដូច្នេះហើយទើបអាពាហ៍ពិពាហ៍របស់ប្អូនស្រីខ្ញុំ អាចប្រព្រឹត្តតាមប្រពៃណីខ្មែរខ្លះៗបាន ។ ក៏ប៉ុន្តែ ពួកខ្មែរក្រហមចាប់ផ្តើមគាបសង្កត់ប្រជាពលរដ្ឋ មិនឲ្យមានសេរីភាពសំដែងមតិ សេរីភាពក្នុងការរួមប្រជុំ និង ខាងជំនឿជាបណ្តើរៗហើយ ។ ព្រះសង្ឃត្រូវរៀនសូត្រខាងនយោបាយ និង ត្រូវជួយរដ្ឋអំណាច ដើម្បីប្រមែប្រមូលប្រជាពលរដ្ឋឲ្យគាំទ្រសម្តេច សីហនុ ជាពិសេស គាំទ្ររដ្ឋអំណាចខ្មែរក្រហមប្រឆាំងនឹង "ចក្រពត្រិអាមេរិក និង បរិវារវា" គឺ ពួកលន់ នល់ ។ យុវជន ឬ យុវតី ជាដំបូងត្រូវឃោសនាបញ្ចុះបញ្ចូលឲ្យចូលទៅបំរើកងទ័ព "សម្តេចឳ" តែក្រោយៗមក ត្រូវកេណ្ឌឲ្យទៅបំរើកងទ័ពខ្មែរក្រហម ។

ការឃោសនាបញ្ចុះបញ្ចូលរបស់ខ្មែរក្រហមកាលនោះ មានប្រសិទ្ធិភាពណាស់ ។ យ៉ាងនោះហើយ ទើបមានយុវជន យុវតី ស្ម័គ្រចិត្តចូលបំរើកងទ័ពយ៉ាងគគ្រឹកគគ្រេង ។ កាលសម័យនោះ នៅក្នុងតំបន់ដែលគេហៅថាតំបន់រំដោះនោះ ការកាន់កាំភ្លើង និង ស្លៀកពាក់ខោអាវខ្មៅ ហាក់ដូចជាម៉ូតទំនើបជាទីពេញនិយមរបស់កំលោះក្រមុំជាច្រើន ។ ពួកគេបាក់ចិត្តធ្វើតាមគ្នា និង បបួលគ្នាថតរូបក្នុងសំលៀកបំពាក់ខ្មៅដៃកាន់កាំភ្លើងទុកជាអនុស្សាវរីយ៍ផង ។ ប្រហែលជាដោយសារ

ការបាក់ចិត្តយ៉ាងនេះហើយ ទើបប្អូនស្រីខ្ញុំខកខានមិនបានមករួមរស់ជាមួយពួកយើងនៅឯភ្នំពេញ ហើយសុខចិត្តរៀបការ និង រស់នៅក្នុងភូមិស្នាយពលជារៀងរហូត ។

ប៉ុន្មានខែក្រោយពីពិធីរៀបអាពាហ៍ពិពាហ៍ប្អូនស្រីខ្ញុំនោះមក ឪពុកខ្ញុំ និង ប្អូនប្រុសខ្ញុំពីរនាក់ទៀតគឺ វណ្ណៈ និង ណារើន បានគេចផុតពីការត្រួតពិនិត្យរបស់ខ្មែរក្រហម ហើយបានមកជួបជុំជាមួយពួកយើងវិញនៅភ្នំពេញ ដោយសារក្លែងខ្លួនជាអ្នកនេសាទជិះទូកតូចរកត្រីតាមស្ទឹង និង ទន្លេ ។ ដំណើរគេចខ្លួនពីភូមិកំណើតរបស់ឪពុកខ្ញុំ និង ប្អូនខ្ញុំ ប្រកបដោយគ្រោះថ្នាក់ជាទីបំផុត ព្រោះកងកំលាំងរបស់លន់ នល់ ប្រើយន្តហោះវាយប្រហារ ដោយគ្រាប់មីស៊ីល ឬ ទម្លាក់គ្រាប់បែកទៅលើទីដៅណា ដែលពួកគេសង្ស័យថាជាខ្មាំងគឺ ពួកវៀតកុង ឬ ពួកខ្មែរក្រហម ។ ទូកតូចរបស់ឪពុកខ្ញុំនោះ ក៏ត្រូវរងនូវការបាញ់រះដែរ ។ ក៏ប៉ុន្តែ នៅទីបំផុត ប្រហែលជាអ្នកបើកបរយន្តហោះចម្បាំងមើលឃើញផ្ទាល់ភ្នែកថា ទូកតូចនោះជាទូកនេសាទដោយគ្មានអ្វីដែលគួរឲ្យបារម្ភទេ ទើបគេឈប់បាញ់រះ និង ទុកទូកនោះឲ្យចូលដល់តំបន់ដែលគ្រប់គ្រងដោយរដ្ឋអំណាច លន់ នល់ ។ នៅពេលមកដល់ភ្នំពេញប្អូនប្រុសខ្ញុំ វណ្ណៈ គ្របមុខដោយក្រមាមិនឲ្យអ្នកណាឃើញមុខគេទេ ។ នៅពេលដែលខ្ញុំបើកក្រមាមើលទៅមុខវានោះ ខ្ញុំមានសេចក្ដីតក់ស្លុតយ៉ាងខ្លាំង ព្រោះរង្វង់មុខដ៏ក្មេងខ្ចីរបស់វា ត្រូវមានស្នាមឆេះរោលរាលខ្មៅពេញមុខ ។ ខ្ញុំនឹកថា ប្អូនប្រុសត្រូវរងគ្រោះ ដោយការទម្លាក់គ្រាប់បែក ឬ បាញ់រះដោយយន្តហោះ ឬ រងគ្រោះដោយសារសង្គ្រាមមិនខានឡើយ ។ យើងបានធូរចិត្តបន្តិចក្នុងមួយនាទីក្រោយមកនៅពេលដែលដឹងថាមុខវណ្ណៈ ត្រូវឆេះរោលរាលដោយសារល្បែងលេងជាមួយប្រេងសាំង មិនមែនរងគ្រោះដោយសារសង្គ្រាមនោះទេ ។ នៅពេលពួកគេមកដល់ទីក្រុងភ្នំពេញនោះ ខ្ញុំសុំច្បាប់ឈប់សម្រាកពីការងារពេញមួយថ្ងៃ ដើម្បីបានជួបជុំគ្នា ។

ជាការល្អដែរ ដែលយើងទើបនឹងពង្រីកផ្ទះយើងឲ្យធំជាងមុន ដែលអាចឲ្យយើងទទួលសមាជិកថ្មី ដែលទើបតែមកដល់នោះ ។

## រៀបការបងប្រុសទី១

អស់រយៈពេលដ៏យូរមកហើយ ដែលយើងចង់ឲ្យបងប្រុសទីមួយរបស់យើង គឺបងឈឿនមានគូស្រករ ។ យើងរង់ចាំវត្តមានរបស់ឪពុកយើង ដើម្បីគិតគូរសំរេចរឿងដ៏សំខាន់នេះ ។ ឥឡូវគាត់បានមកដល់ភ្នំពេញ ដូច្នេះសម្រាប់ពួកយើងពេលវេលាបានមកដល់ហើយ ។ មុនពេលឪពុកខ្ញុំមកដល់ បងប្រុសខ្ញុំបានបង្ហាញពីការសម្រេចចិត្តរបស់គាត់រួចទៅហើយគឺ គាត់សំដៅចំលើមិត្តនារី ដែលជាគ្រូបង្រៀន ហើយដែលធ្លាប់បានរៀនជាមួយគ្នានៅកំពង់កន្ទួតឈ្មោះអ្នកគ្រូ ស៊ីណាត ។ ឪពុកខ្ញុំមិនជំទាស់ចំពោះការសម្រេចចិត្តនោះទេ ។ ដូច្នេះ មួយខែក្រោយមក យើងក៏រៀបចំពិធីអាពាហ៍ពិពាហ៍របស់បងប្រុសខ្ញុំ ។ សម្រាប់ពិធីនេះ ខ្ញុំមានភារកិច្ចទទួលខុសត្រូវផ្នែកភេសជ្ជៈ ដោយសារតាមរយៈមិត្តភក្តិដែលខ្ញុំមាននៅក្នុងក្រុមហ៊ុនសុរាគារខ្មែរ ខ្ញុំអាចរកបាននូវសុរាល្អៗ ដែលមានតម្លៃសមរម្យ ។ ពួកយើងសម្រេចជ្រើសរើសយកស្រារ៉ូម ណេហ្គ្រីតា (Negreta) លាយជាមួយសូដា និង ទឹកកកសម្រាប់ពិធីជប់លៀង នៅក្នុងភោជនីយដ្ឋានធំមួយនៅម្តុំផ្សារចាស់ ។ នៅក្នុងឱកាសនោះ បងប្រុសទីពីររបស់ខ្ញុំ បងស៊ីនឿន បានអញ្ជើញគ្រូជនជាតិបារាំងរបស់គាត់ពីរនាក់ឲ្យមកចូលរួម ។ គ្រូបារាំងម្នាក់បានប្រើប្រាស់កាមេរ៉ាថតខ្សែភាពយន្តទំហំ ១៦ មម របស់គាត់ (Camera) ដើម្បីថតពិធីជប់លៀងទាំងមូលផង ។ ខ្សែភាពយន្តនោះមានប្រជាប្រិយភាពជាខ្លាំង នៅពេលដែលពួកយើងយកមកបញ្ចាំងឲ្យបងប្អូន និង ញាតិមិត្តដែលបានចូលរួមក្នុងពិធីជប់លៀងទស្សនានៅពេលក្រោយៗមក ។

បងប្រុសទី១របស់ខ្ញុំពូកែធ្វើការទាក់ទងណាស់ ។ មួយខែក្រោយពីរៀបការមក គាត់ទទួលបាននូវការអនុញ្ញាតឲ្យករិយាថ្មោងថ្មីរបស់គាត់ បានផ្លាស់មកបង្រៀននៅសាលាជាមួយគាត់ ក្បែររាជធានីភ្នំពេញដែរ ។ ដូច្នេះ ផ្ទះយើងក៏ទទួលបាននូវសមាជិកថ្មីទៀត ។ យើងមានគ្នាកាន់តែច្រើនឡើងៗ ព្រោះថាគ្រួសារខាងបងថ្លៃខ្ញុំ ក៏បានមករួមរស់ជាមួយពួកយើងថែមទៀត ។ ដោយសារសង្គ្រាម ជីវភាពយើងក៏កាន់តែមានការលំបាកដែរ ។ មនុស្សម្នាកាន់តែមានចំនួនច្រើនឡើង នាំឲ្យមានការលំបាកក្នុងការផ្គត់ផ្គង់ជាអនេកកប្បការ ។

## ចូលធ្វើការក្នុងក្រុមហ៊ុនឯកជន

នៅខែ កុម្ភៈ ១៩៧១ ខ្ញុំឈប់ធ្វើការនៅក្នុងក្រុមហ៊ុនសុរាគារខ្មែរទៀតហើយ ដោយខ្ញុំរកការបានធ្វើនៅក្នុងក្រុមហ៊ុនសូគីឡេ (Sokilait) ។ កាលនោះបន្ទាប់ពីបានទម្លាក់សម្តេច សីហនុ ពីអំណាច រដ្ឋាភិបាល លន់ នល់ បានចាប់ផ្តើមអនុវត្ត នយោបាយបណ្តេញជនជាតិវៀតណាមឲ្យចេញពីកម្ពុជា ។ ជនជាតិវៀតណាមដែលត្រូវចាប់ខ្លួន ត្រូវប្រមូលឲ្យនៅក្នុងជំរុំ រួចត្រៀមបញ្ជូនទៅប្រទេសវៀតណាមវិញ ។ ជនជាតិវៀតណាម ដែលគេរកឃើញរស់នៅក្រៅជំរុំជនគៀសខ្លួនអាចទទួលនូវការបង្ក្រាបពីអាជ្ញាធរ ។ ដោយសារមានការភ័យខ្លាចយ៉ាងខ្លាំង នោះទើបលោកគ្រូជនជាតិបារាំងរបស់បងខ្ញុំ ដែលមានសង្សារជាស្ត្រីជនជាតិវៀតណាមដ៏ក្មេងខ្ចីមួយនាក់ផងនោះ បានមកសុំឲ្យពួកយើងរកវិធីជួយរំដោះនាងឲ្យចេញផុតពីរាជធានីភ្នំពេញ ទៅរកទីកន្លែងដែលមានសុវត្ថិភាព ។ យើងបានសុខចិត្តជួយរំដោះសង្សាររបស់លោកគ្រូបារាំងនោះ ។ យើងឲ្យស្ត្រីវៀតណាមនោះស្លៀកសារ៉ុងបន្លំជាស្ត្រីខ្មែរ និង ហាមកុំឲ្យនិយាយស្តីអ្វីសោះ នៅពេលយើងឆ្លងកាត់ប៉ុស្តិ៍ត្រួតពិនិត្យរបស់ក្រុមតម្រួតយោធាដែលនៅជាបន្តបន្ទាប់តាមផ្លូវ ។ ពួកយើងមានភ័ព្វ

សំណាងណាស់ ព្រោះឆ្លងកាត់តំបន់ត្រួតពិនិត្យដោយពុំមានជួបប្រទះនូវឧបសគ្គអ្វីទាំងអស់ រហូតទៅដល់ "អ្នកលឿង" ដែលជាទីដៅនៃដំណើររបស់យើង ។ ស្ត្រីក្មេងជនជាតិវៀតណាមនោះ បានជួបនឹងគ្រួសាររបស់នាងនៅអ្នកលឿង ហើយបានសំដែងអំណរគុណដ៏រំភើប ចំពោះពួកយើង ។ ដោយសារការបណ្តេញជនជាតិវៀតណាមចេញពីកម្ពុជាយ៉ាងនេះហើយ ទើបជនជាតិវៀតណាម ដែលធ្វើការជាគណនេយ្យករនៅក្នុងក្រុមហ៊ុន សូគីឡេ (Sokilait) បានបង្ខំចិត្តលះបង់ការងារ ហើយបានទទួលទិដ្ឋាការទៅរស់នៅឯប្រទេសបារាំង ។ ដោយសារក្រុមហ៊ុនត្រូវការគណនេយ្យករជាចាំបាច់ខានពុំបាន ទើបគេជ្រើសរើសខ្ញុំឲ្យចូលមកជំនួសជនជាតិវៀតណាមនោះទៅ ។

នៅក្នុងក្រុមហ៊ុនថ្មីនេះ ខ្ញុំបានរៀនសូត្ររបៀបរបបធ្វើការថ្មីៗទៀត ព្រោះម្តងនេះ ខ្ញុំធ្វើការក្នុងក្រុមហ៊ុនឯកជនសុទ្ធសាធតែម្តង ដែលតម្រូវឲ្យយើងមានប្រសិទ្ធភាពក្នុងការងារច្បាស់លាស់ពិតប្រាកដ ។ បើប្រៀបធៀបទៅនឹងក្រុមហ៊ុនសុរាគារខ្មែរ ដែលខ្ញុំបានសន្មត់ថារបៀបរបបការងារមានលក្ខណៈសកម្មជាងនៅក្នុងមន្ទីរ ឬ ក្រសួងនានានៃរដ្ឋាភិបាលរួចទៅហើយនោះ ខ្ញុំក៏ឃើញថាការងារនៅសូគីឡេ មានប្រសិទ្ធិភាពខ្ពស់ ហើយបុគ្គលិកគ្រប់គ្នាសុទ្ធតែប្រញឹកក្នុងការងារគ្មានពេលនិយាយគ្នាលេងឥតប្រយោជន៍មួយនាទីណាឡើយ ។ សូគីឡេមានការគ្រប់គ្រងតាមបទដ្ឋានអន្តរជាតិ ដោយសារក្រុមហ៊ុននេះមានភាគហ៊ុនអន្តរជាតិមកពីប្រទេសដាណឺម៉ាក អូស្ត្រាលី ស៊ុយអែត និង ខ្មែរ ។ ប្រធានធំរបស់ក្រុមហ៊ុនមេ[26] ជាជនជាតិដាណឺម៉ាក ដែលកាន់តំណែងជាកុងស៊ុលតំណាងផលប្រយោជន៍ប្រទេសដាណឺម៉ាក នៅព្រះរាជាណាចក្រកម្ពុជាផង ។ លោកកុងស៊ុល ជាប្រធានអគ្គនាយក ចំណែកអគ្គនាយករង ជាជនជាតិស៊ុយអែត ។ ថ្នាក់ដឹកនាំដែលមាន

---

[26] Société mère គឺក្រុមហ៊ុនដែលបង្កើតក្រុមហ៊ុនឯទៀត ។

សញ្ជាតិជាណឺម៉ាក មានតួនាទីទទួលខុសត្រូវផ្នែកគ្រប់គ្រង ឯពពួកជនជាតិអូស្ត្រាលី មានភារកិច្ចខាងផលិតកម្ម ខាងថែទាំ ខាងត្រួតពិនិត្យគុណភាព និង ខាងផ្នែកស្រាវជ្រាវ ។ ខ្ញុំចូលចិត្តពួកអូស្ត្រាលីណាស់ ដោយឃើញគេប្រឡូកធ្វើការដោយផ្ទាល់ជាមួយពួកកម្មករខ្មែរ ។ ពួកគេមិនប្រកាន់ខ្លួនឡើយ ទោះបីជាពួកគេសុទ្ធសឹងជាវិស្វករមានជំនាញខ្ពស់យ៉ាងណាក៏ដោយ ។ ខ្ញុំនឹកក្នុងចិត្តថា ប្រសិនបើខ្មែរយើងវិញ បើមានឋានៈជាវិស្វករទៅហើយនោះ មិនងាយនឹងចូលមកប្រឡូកផ្ទាល់ក្នុងការងារជាមួយពួកកម្មករឡើយ ព្រោះតាមទម្លាប់កន្លងមក ពួកវិស្វករខ្មែរភាគច្រើនចាំតែលូកហោប៉ៅខោស្រែកបញ្ជាពីចម្ងាយតែប៉ុណ្ណោះ ។ ទាំងនេះជាការសង្កេតរបស់ខ្ញុំនាសម័យនោះ ។

ខ្ញុំបានត្រូវជ្រើសរើសឲ្យចូលធ្វើការនៅសូគីឡេ ជំនួសគណនេយ្យករវៀតណាមនោះ ដោយលោកនាយគណនេយ្យករម្នាក់ឈ្មោះ លន់ មាន ដែលធ្លាប់បានរៀនសូត្រនៅសាលាពាណិជ្ជកម្មដែរ ហើយមានបំណងចង់បានគណនេយ្យករក្មេងម្នាក់ ដែលមានបទពិសោធន៍គ្រប់គ្រាន់ និង មានចិត្តស្វិតស្វាញក្នុងការងារ ។ ខ្ញុំឮគេថាលោក លន់ មាន ជាប់ជាសាច់ញាតិជាមួយលោក លន់ នល់ ផង ដូច្នេះហើយទើបគាត់មានទំនាក់ទំនងល្អជាមួយមន្ត្រីថ្នាក់ដឹកនាំធនាគាររដ្ឋ និង ក្រសួងសំខាន់ៗដូចជាក្រសួងសេដ្ឋកិច្ច និង ពាណិជ្ជកម្មជាដើម ។ លោកនាយប្រើពេលវេលារបស់គាត់ភាគច្រើនក្នុងទំនាក់ទំនងសាធារណៈ ច្រើនជាងកិច្ចការខាងគណនេយ្យ ព្រោះក្រុមហ៊ុនត្រូវការចរចាជាមួយរដ្ឋាភិបាល ឬ ធនាគារដើម្បីទទួលឲ្យបាននូវភាពអនុគ្រោះសំខាន់ៗ សំរាប់ក្រុមហ៊ុនដូចជាប្រាក់កម្ចីបន្ថែមពីធនាគារ អាជ្ញាប័ណ្ណនាំចេញនាំចូល ឬ ការទូទាត់តម្លៃទំនិញ ដែលរដ្ឋាភិបាលអាចផ្តល់មកក្រុមហ៊ុន។ល។ កាលពីសម័យសង្គមរាស្ត្រនិយម វិស័យធនាគារត្រូវបានធ្វើជាតូបនីយកម្មទាំងអស់ ពុំមានធនាគារឯកជនទេ ។ នៅក្រោយពេលដែលលោក

លន់ នល់ ឡើងកាន់អំណាច ប្រទេសយើងក៏ចាប់ផ្តើមទទួលបាននូវការវិនិយោគទុនឯកជនមួយចំនួន ។ ក៏ប៉ុន្តែ ក្រុមហ៊ុនស៊ូគីឡេ នៅតែបន្តធ្វើការជាមួយធនាគាររដ្ឋដ៏ធំមួយឈ្មោះ ធនាគារខ្មែរសំរាប់ពាណិជ្ជកម្ម ។ តាមរយៈទំនាក់ទំនងល្អក្រុមហ៊ុនក៏ទទួលបានប្រាក់កម្ចីច្រើន ឬ ក៏ត្រូវអនុញ្ញាតឲ្យពន្យារពេលសងប្រាក់ជំពាក់ជាច្រើនលើកច្រើនគ្រា ។ ក្រៅពីសេចក្តីត្រូវការខាងផ្នែកសាច់ប្រាក់ក្រុមហ៊ុនក៏នៅត្រូវការនាំចូលឲ្យបានឆាប់ៗនូវសំភារៈ ឬវត្ថុធាតុដើមជាច្រើនទៀត ។ ម្យ៉ាងទៀត បើតាមខ្ញុំចាំមានតែក្រុមហ៊ុនស៊ូគីឡេទេ ដែលមានភ័ព្វសំណាងបានទទួលប្រាក់សំណងពីក្រសួងពាណិជ្ជកម្ម នៅពេលដែលតម្លៃផលិតទឹកដោះគោឡើងខ្ពស់ពីតម្លៃដែលក្រសួងកំណត់ឲ្យលក់នៅលើទីផ្សារ ។ ក្នុងសម័យសង្គ្រាម អតិផរណាចេះតែកើនឡើងរាល់ថ្ងៃ ដូច្នេះតំលៃទំនិញនៅលើទីផ្សារ ចេះតែកើនឡើងឥតឈប់ឈរ ។ ក្រសួងពាណិជ្ជកម្មមានគោលនយោបាយកំណត់តម្លៃទំនិញចាំបាច់ទាំងឡាយមិនឲ្យឡើងហួសហេតុផលពេក ជាពិសេសតម្លៃទឹកដោះគោ ។ ក្នុងទំនាក់ទំនងនេះ លោក លន់ មាន បានទទួលការគ្រាំទ្រដ៏រឹងមាំពីថ្នាក់ដឹកនាំក្រុមហ៊ុន ។ មួយថ្ងៃៗ គាត់ត្រូវបានអនុញ្ញាតឲ្យដកសាច់ប្រាក់ជាច្រើនសន្ធឹកសន្ធាប់ដើម្បីយកទៅជប់លៀង ឬ សូកមន្ត្រីធំៗរបស់ធនាគារ ឬ របស់ក្រសួងនានាដែលក្រុមហ៊ុនត្រូវការភាពអនុគ្រោះ ។ ជាមួយគ្នានោះ ក្រុមហ៊ុនក៏បានបង្កើតផ្នែកស្វែងរកទីផ្សារ (Marketing Department) ដែលមានស្ត្រីក្មេងៗស្លៀកសំលៀកបំពាក់ឯកសណ្ឋានដ៏ស្រស់ស្អាតនៅធ្វើការងារជាប្រចាំ ។ ពួកស្ត្រីទាំងនោះ ចេះនិយាយភាសាបរទេសយ៉ាងស្ទាត់ជំនាញ ទាំងភាសាបារាំង ទាំងភាសាអង់គ្លេស ឬ ចិន ។ ពួកនាងៗទាំងនោះមួយភាគធំសុទ្ធតែចេញពីសាលាបារាំង ឬ មកពីបរទេស ។ ក្នុងចំណោមនោះ មានស្ត្រីក្មេងៗពីរនាក់ជាចិនកន្តាំង ឬ ចិនតៃវ៉ាន់ ។ ខ្ញុំឮគេនិយាយថា នាងទាំងពីរនាក់នោះ មានភារកិច្ចសំខាន់គឺទាក់ទាញអារម្មណ៍ ឬ បំរើសេវាគ្រប់យ៉ាង

កំដរថ្នាក់ដឹកនាំក្រសួង មានដូចជារដ្ឋមន្ត្រីច្រើនជាងការងារស្វែងរកទីផ្សារ ។

## និយាយគ្នាតាមវចនានុក្រម

បន្ទាប់ពីខ្ញុំធ្វើការបាន ៦ ខែ លោក លន់ មាន ត្រូវផ្លាស់ចេញទៅកាន់តំណែងផ្សេង ហើយគាត់ត្រូវជំនួសដោយនាយគណនេយ្យករថ្មី ដែលមានសញ្ជាតិជាណឺម៉ាក[27] ។ លោកនាយថ្មី មិនចេះនិយាយភាសាបរទេសអ្វីផ្សេង ក្រៅពីភាសាអង់គ្លេស បន្ថែមលើភាសាដាណាម៉ាក ដែលជាភាសាកំណើតរបស់គាត់ ។ នៅពេលនោះ ខ្ញុំមិនទាន់ចេះនិយាយភាសាអង់គ្លេសនៅឡើយទេ ខ្ញុំចេះតែភាសាខ្មែរ និង បារាំងប៉ុណ្ណោះ ។ ដូច្នេះ ខ្ញុំត្រូវការអ្នកបកប្រែភាសាក្នុងការងារជាមួយលោកនាយរបស់ខ្ញុំ ។ ដើម្បីសំរួលការងាររបស់យើង ក្រុមហ៊ុនបានជ្រើសរើសអ្នកបកប្រែម្នាក់ ។ អ្នកបកប្រែនោះ គ្រាន់តែចេះភាសាអង់គ្លេសតែមិនមានបទពិសោធន៍ណាសោះក្នុងកិច្ចការហិរញ្ញវត្ថុ និង គណនេយ្យ ។ ជាច្រើនលើកច្រើនសារ ខ្ញុំទទួលបាននូវការបកប្រែមិនច្បាស់លាស់ ចំពោះការណែនាំរបស់លោកនាយ ជាហេតុឲ្យពួកយើងមានការលំបាកក្នុងការងារ ។ នៅទីបំផុត លោកនាយ និង ខ្ញុំ យើងទាំងពីរនាក់ សម្រេចចិត្តមិនត្រូវការអ្នកបកប្រែភាសាទៀតទេ ។ យើងប្រើវចនានុក្រមបារាំង-អង់គ្លេសចំនួនពីរក្បាល មួយក្បាលសម្រាប់លោកនាយ មួយក្បាលទៀតសំរាប់ខ្ញុំ ។ បើខ្ញុំចង់ពន្យល់អ្វី ខ្ញុំបើកវចនានុក្រមលើពាក្យបារាំង ដែលមានបកប្រែភាសាអង់គ្លេសបង្ហាញទៅគាត់ បើលោកនាយចង់ពន្យល់អ្វីមកខ្ញុំ គាត់បើកវចនានុក្រម លើពាក្យអង់គ្លេសដែលមានបកប្រែជាបារាំងបង្ហាញមកខ្ញុំទៅវិញទៅមក ។ ក៏ប៉ុន្តែ យើងទាំងពីរនាក់ប្ដេជ្ញាចិត្តរៀងៗខ្លួនថាក្នុងរយៈពេលមួយឆ្នាំ ខ្ញុំត្រូវចេះភាសា

[27] លោកប្រធានក្រុមគណនេយ្យនោះឈ្មោះ E. W. N. Eichmeyer.

អង់គ្លេស ឯលោកនាយត្រូវចេះភាសាបារាំង ។ យើងធ្វើយ៉ាងនេះ ក្នុងរយៈពេលពេញមួយឆ្នាំ ។ ក្នុងរយៈពេលមួយឆ្នាំនេះ ខ្ញុំខិតខំរៀនភាសាអង់គ្លេសដោយខ្លួនឯង តាមរយៈខ្សែអាត់សម្លេង និង ការអានសៀវភៅ ។ នៅពេលដែលខ្ញុំអាចនិយាយភាសាអង់គ្លេសបានខ្លះៗនោះ ពួកយើងចាប់ផ្ដើមដណ្ដើមគ្នានិយាយគឺ នៅពេល ដែលខ្ញុំនិយាយអង់គ្លេស លោកនាយនិយាយភាសាបារាំងមកវិញ ។ មិនយូរប៉ុន្មាន យើងក៏អាចនិយាយទាក់ទងគ្នាជាភាសាអង់គ្លេសបាន ឯលោកនាយរបស់ខ្ញុំនៅតែបន្តនិយាយភាសាបារាំងបានយ៉ាងរដិបរដុបតទៅទៀត ។ ខ្ញុំរក្សាមិត្តភាពដ៏ជិតស្និទ្ធ បានល្អណាស់ជាមួយនាយចៅហ្វាយរបស់ខ្ញុំ រហូតដល់ពេលដែលខ្ញុំបែកចេញទៅរស់នៅឯប្រទេសបារាំង ។

នៅសម័យនោះ ខ្ញុំអាចនិយាយបានថា ខ្ញុំមានការចងចាំល្អ ជាពិសេសចងចាំខាងលេខ ឬ ចំនួនដែលអាចឲ្យខ្ញុំឆ្លើយភ្លាមៗ ចំពោះសំណួរទាក់ទងទៅនឹងចំនួនប្រាក់កាសចំណូលចំណាយ និង លេខគណនីយ ដែលគេចងក្រងជាផែនការគណនេយ្យ (Plan Comptable) ដែលមានលេខជាច្រើនខ្ទង់ ។ ម្យ៉ាងទៀត ខ្ញុំក៏រៀនភាសាបរទេសឆាប់ចេះណាស់ដែរ ដូចជាភាសាអ៊ីតាលី ដែលខ្ញុំអាចសរសេរសំបុត្រឆ្លើយឆ្លងបន្តិចបន្តួចបាន ក្រោយពីបានរៀនខ្លួនឯងតាមរយៈសៀវភៅមេរៀន ដែលមានខ្សែអាត់ថតសម្លេងក្នុងរយៈពេលដ៏ខ្លី ។ ក៏ប៉ុន្តែ ខ្ញុំមានចំណុចខ្សោយមួយដ៏ធំគឺ ខ្ញុំមិនព្យាយាមរៀនឱ្យបានវែងឆ្ងាយ ឬ ជ្រៅជ្រះគឺ គ្រាន់តែមួយឆាវៗ រួចក៏រលត់បាត់អស់ទៅ ។

## មន្ត្រីពន្ធដារសួរថា "រៀបចំរួចស្រេចហើយឬនៅ?"

មុនពេលលោក លន់ មាន ត្រូវប្ដូរមុខតំណែងចេញពីផ្នែកគណនេយ្យគាត់បានអនុញ្ញាតឲ្យខ្ញុំទៅ ធ្វើការក្រៅម៉ោងបន្ថែមនៅក្នុងក្រុមហ៊ុនឯកជនពីរទៀតដែល

មានក្រុមហ៊ុនមេជារបស់បារាំង ។ ក្រុមហ៊ុនមួយ មានទីតាំងនៅក្បែរសូគីឡេដែរ ។ ដូច្នេះ នៅពេលថ្ងៃត្រង់ ពេលសម្រាកការងារនៅសូគីឡេ ខ្ញុំក៏ប្រញាប់ប្រញាល់ទៅធ្វើការបន្ថែមនៅក្នុងក្រុមហ៊ុនបារាំងនោះ ។ ក្រុមហ៊ុនមួយទៀតមានទីតាំងនៅតាមមហាវិថីព្រះនរោត្តម ។ រាល់ពេលល្ងាច កាលណាខ្ញុំចេញពីសូគីឡេ ខ្ញុំត្រូវបន្តការងារនៅក្រុមហ៊ុនបារាំងមួយនោះទៀត រហូតម៉ោងប្រមាណប្រាំបួនយប់ ។ ខ្ញុំធ្វើការផ្ទាល់ជាមួយនាយកក្រុមហ៊ុនដែលជាជនជាតិបារាំង បន្ទាប់ពីគណនេយ្យកររបស់ក្រុមហ៊ុនដែលជាជនជាតិវៀតណាមរបស់ក្រុមហ៊ុននោះ បានបោះបង់ចោលការងារ ដោយត្រូវបង្ខំចិត្តត្រឡប់ទៅស្រុកគេវិញ តាមនយោបាយរបស់រដ្ឋាភិបាល លន់ នល់ បន្ទាប់ពីព្រឹត្តិការណ៍ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ ។ អស់រយៈពេលមួយឆ្នាំមកហើយដែលក្រុមហ៊ុនគ្មានគណនេយ្យករធ្វើការ ហើយការងារផ្នែកគណនេយ្យនេះ ក៏ចេះតែកើនឡើងគរជាគំនររៀងរាល់ថ្ងៃ ។ ខ្ញុំមានភារកិច្ចរៀបចំបញ្ជីស្នាមរបស់ក្រុមហ៊ុនឲ្យមានសណ្តាប់ធ្នាប់ឡើងវិញ ។ ក្នុងរយៈពេលជាងមួយឆ្នាំកន្លងមកហើយនោះ ក្រុមហ៊ុនបារាំងទាំងពីរពុំដែលបានបង់ពន្ធអ្វីឡើយ ។ ដូច្នេះ ខ្ញុំត្រូវរៀបចំឯកសារគណនេយ្យឲ្យបានត្រឹមត្រូវទាន់ពេលវេលា និង ត្រូវគិតគូរបង់ពន្ធជូនរដ្ឋតាមច្បាប់ផង ។ នៅសម័យ លន់ នល់ នោះ ប្រទេសយើងជួបប្រទះនូវអំពើពុករលួយយ៉ាងធ្ងន់ធ្ងរ ។ ចំពោះខ្ញុំ ដែលមិនធ្លាប់មានទំនាក់ទំនងជាមួយផ្នែករដ្ឋការ ខ្ញុំមិនបានយល់ពីរបៀបរបបការងារដែលត្រូវធ្វើឡើងជាមួយមន្ទីរ ឬ ក្រសួងនាសម័យនោះឡើយ ។

តាមពិតនៅសម័យនោះ ការបង់ពន្ធដារ មិនមានការអ្វីពិបាកនោះទេគឺ គេគ្រាន់តែចរចាជាមួយមន្ត្រីពន្ធដារឲ្យត្រូវរ៉ូវគ្នាទៅក៏រួចគ្នាទៅហើយ ។ បើត្រូវបង់ ១០០ យើងអាចចរចាបង់តែ ៥០ ឬ ៦០ ដោយជូនជាសាគុណមួយផ្នែកដល់មន្ត្រីទទួលខុសត្រូវនោះ ។ ថ្ងៃមួយ ខ្ញុំបានណាត់ពេលសុំជួបមន្ត្រីពន្ធដារ ដើម្បីនាំយក

បញ្ជីនាំចូល និង បញ្ជីចំណូលទៅជូនគាត់ពិនិត្យក្នុងការវាយតម្លៃនាំចូលដែលក្រុមហ៊ុនបារាំងត្រូវបង់ជូនរដ្ឋ ។ នៅថ្ងៃដែលកំណត់ត្រូវជួបគ្នានោះ ខ្ញុំបានបង្ហាញបញ្ជីសៀវភៅជូនមន្ត្រីពន្ធដារពិនិត្យ ។ នៅពេលចាប់ផ្តើមមន្ត្រីនោះសួរខ្ញុំថា "អ្វីៗរៀបចំស្រេចហើយឬនៅ?" ខ្ញុំឆ្លើយថា "បាទទាន" ដោយនឹកថា ការងារដែលខ្ញុំធ្វើនោះបានរៀបចំស្រេចបាច់ហើយ ។ ក៏ប៉ុន្តែ មន្ត្រីពន្ធដារនោះ នៅតែបន្តសួរខ្ញុំដដែលថា "អ្វីៗរៀបចំស្រេចហើយឬៗនៅ?" នៅពេលដែលគាត់បើកសៀវភៅពីទំព័រមួយទៅទំព័រមួយ ។ តាមពិត ខ្ញុំមិនបានយល់អំពីភាសារបស់គាត់ដែលធ្លាប់និយាយទៅកាន់អ្នកឯទៀតដែលមានបទពិសោធន៍ច្បាស់លាស់ ។ តាមពិតអ្វីដែលមន្ត្រីនោះចង់និយាយគឺ គាត់ចង់សួរថា តើខ្ញុំបានត្រៀមស្រោមសំបុត្រទុកនៅក្នុងចន្លោះទំព័រសៀវភៅនោះហើយឬនៅ? ដូច្នេះហើយ ទើបគាត់ចេះតែសួរដដែលៗនៅពេលដែលខ្ញុំឆ្លើយថា "បាទទានៗ" ។ ដោយសារមិនឃើញមានស្រោមសំបុត្រនោះ យើងពុំបានសំរេចការងារអ្វីឡើយ ហើយត្រូវណាត់ពេលនៅថ្ងៃក្រោយទៀត ។ បីអាទិត្យក្រោយមក ខ្ញុំក៏ទៅជួបមន្ត្រីនោះសាជាថ្មី ជាមួយនិងស្រោមសំបុត្រប្រកបដោយប្រាក់មួយចំនួនផង ។ លើកនេះការងាររបស់យើងបានប្រព្រឹត្តទៅយ៉ាងរលូន និង ឆាប់រហ័ស ដោយគ្មានបញ្ហាអ្វីធំដុំឡើយ ។

## មានគណនីនៅក្រេឌីលីយ៉ោណេ[28]

ក្នុងសម័យនោះ ខ្ញុំមានការងារជាប់រវល់យ៉ាងមមាញឹក ។ ខ្ញុំពុំសូវមានឱកាសបានជួបមុខឪពុកម្តាយ បងប្អូនដែលរស់នៅភ្នំពេញឡើយ ។ ខ្ញុំរកប្រាក់បានល្មមគ្រាន់តែចិញ្ចឹមបងប្អូនញាតិសន្តាន ដែលរស់នៅជាមួយខ្ញុំនៅទីក្រុងភ្នំពេញ

[28] Crédit Lyonais ក្រេឌីលីយ៉ោណេ ជាធនាគារដ៏ធំមួយនៅប្រទេសបារាំង ។

ដែលកាន់តែមានចំនួនច្រើនឡើងៗដោយសារនាំគ្នាគេចពីសង្គ្រាម និង គ្រាន់តែទប់ទល់ទំនិញឡើងថ្លៃជារៀងរាល់ថ្ងៃ ដែលជានិច្ចជាកាលឡើងលឿនជាងប្រាក់ចំណូលរបស់យើងទៀតផង នាសម័យនោះ ។ នៅឆ្នាំ ១៩៧១ ខ្ញុំសន្សំសំចៃប្រាក់បានត្រឹមតែទិញទោចក្រយានយន្តម៉ាកហុកដា (HONDA CP 50) មួយគ្រឿងដែលពួកស្ត្រីភាគច្រើននិយមប្រើប្រាស់ ព្រោះមានភាពងាយស្រួលក្នុងការបើកបរ និង មានតំលៃថោកជាងគេក្នុងចំណោមទោចក្រយានយន្តម៉ាកហុងដា (HONDA) ទាំងអស់ ។ ក្រោយមក ខ្ញុំក៏មានលទ្ធភាពបើកគណនីមួយនៅប្រទេសបារាំងតាមរយៈសំបុត្រឆ្លើយឆ្លង ។ ខ្ញុំមានមោទនភាពណាស់ ដោយទទួលបាននូវមូលប្បទានប័ត្របារាំងរបស់ធនាគារក្រេឌីលីយ៉ោណេ (Crédit Lyonais) ទោះបីជាខ្ញុំមិនដែលបានទៅប្រទេសបារាំង និង មានប្រាក់បន្តិចបន្តួចក្នុងគណនីនោះយ៉ាងណាក៏ដោយ[29] ។

## ក្រុមហ៊ុនកូមិនខ្មែរជាក្រុមហ៊ុនចុងក្រោយ

នៅខែ កញ្ញា ១៩៧២ ខ្ញុំត្រូវបានផ្លាស់ឲ្យទៅធ្វើការនៅក្រុមហ៊ុនមេឈ្មោះកូមិន្ទខ្មែរ (Comin Khmer) ។ ក៏ប៉ុន្តែ ខ្ញុំត្រូវបំរើការងារនៅក្នុងផ្នែកមួយផ្សេងពីផ្នែកគណនេយ្យ ។ ផ្នែកនោះឈ្មោះថា អ៊ី ឌី ភី (E D P) “Electronic Data Processing ” ដែលជាផ្នែកថ្មីទំនើបនៅក្នុងសម័យនោះ ។ ផ្នែកនេះឋិតនៅក្រោមការគ្រប់គ្រងរបស់លោក លៀស ចាន់ថុន ដែលជាបញ្ញវន្តខ្មែរមួយរូបដែលមានបរិញ្ញាប័ត្រមកពីសហរដ្ឋអាមេរិកផ្នែកពាណិជ្ជកម្ម (Bachelor Degree of Business Administration)។ លោក លៀស ចាន់ថុន មានទំនាក់ទំនងជិតស្និទ្ធជាមួយថ្នាក់

[29] តាមពិត នៅក្នុងគណនីនោះ ខ្ញុំមានប្រាក់ចំនួន ៦៧៥ ហ្វ្រង់ ឬ ជាង ២០០ ដុល្លារអាមេរិក ។

ដឹកនាំរបស់ក្រុមហ៊ុន ជាពិសេសក្រុមហ៊ុនស្កង់ឌីណាវ (Scandinave) ។ ខ្ញុំឮគេថា លោក លៀស ចាន់ថុន ជាមន្ត្រីគ្រប់គ្រងមួយរូប ដែលបានផ្តើមគំនិតរៀបចំផ្នែកថ្មីនេះ ។ ខ្ញុំត្រូវទៅធ្វើការនៅឯស្នាក់ការកូមិន្ទខ្មែរ (Comin Khmer) ដែលតាំងនៅតាមវិថីកម្ពុជាក្រោម ដែលជាវិថីមួយមានចរាចរណ៍ណែនណាន់តាន់តាប់ជាប់ជានិច្ច ។ ដូច្នេះ ខ្ញុំទៅធ្វើការនៅទីកន្លែងដែលជិតជាង កាលខ្ញុំនៅឯក្រុមហ៊ុនសូគីឡេ ។

នៅពេលខ្ញុំផ្លាស់មកកូមិន្ទខ្មែរនោះ ខ្ញុំក៏ឈប់ធ្វើការក្រៅម៉ោងឲ្យក្រុមហ៊ុនបារាំងទាំងពីរនោះទៀតហើយ ដោយហេតុថាក្រុមហ៊ុនទាំងពីរនោះ ត្រូវបានបញ្ចប់សកម្មភាពរបស់គេទាំងស្រុងព្រោះតែភ្លើងសង្គ្រាមចេះតែឆេះសន្ធោសន្ធៅឡើងៗ។ មុខងារថ្មីរបស់ខ្ញុំនៅផ្នែកអ៊ី ឌី ភី (E D P) នេះ ជាមុខងារអ្នកត្រួតពិនិត្យ “E D P Controller” តែមួយគត់នៅក្នុងក្រុមហ៊ុន ។ ភារកិច្ចរបស់ខ្ញុំ មានជាអាទិដូចជាចុះលេខកូដរបស់ឯកសារទាំងអស់ត្រួតពិនិត្យមុននឹងបញ្ជូនទៅផ្នែកកុំព្យូទ័រ ។ នៅផ្នែកកុំព្យូទ័រ ប្រសិនបើមានការភ័ន្តច្រឡំ ខ្ញុំត្រូវរកការភ័ន្តច្រឡំនោះឲ្យឃើញ និងកែតម្រូវឡើងវិញ ។ ម្យ៉ាងទៀត ខ្ញុំត្រូវត្រួតពិនិត្យឯកសារកុំព្យូទ័រទាំងឡាយមុននឹងចែកចាយឲ្យប្រើប្រាស់ ។ តាមពិត ក្រុមហ៊ុនកូមិន្ទខ្មែរ ជាក្រុមហ៊ុនទំនើបមួយដែលមានឧបករណ៍អេឡិចត្រូនិកប្រើប្រាស់សំរាប់ការងាររបស់គេ ។ ក៏ប៉ុន្តែកុំព្យូទ័រសម័យនោះ ជាកុំព្យូទ័រធំៗហើយដែលគេប្រើប្រាស់តាមប្រព័ន្ធចោះកាតដែលគេហៅថាកាត ៨២ ខ្ទង់ ។ ក្រោយមក នៅពេលខ្ញុំចេញដំណើរទៅប្រទេសបារាំង ក្រុមហ៊ុនកូមិន្ទខ្មែរ ចាប់ផ្តើមប្រើប្រព័ន្ធថាស (Disk System) ។

ខ្ញុំធ្វើការក្នុងការិយាល័យជាមួយអ្នករៀបរៀងកម្មវិធី (Software Programmer) ម្នាក់ឈ្មោះ ផាន់ សូរិយាស៊ី ដែលទើបតែត្រឡប់មកពីប្រទេសបារាំង ។ សូរិយាស៊ី ជាមនុស្សស្អាតហើយចូលចិត្តស្លៀកពាក់ហ៊ឺហា ។ តាមធម្មតា តុធ្វើការរបស់យើងត្រូវរៀបចំទុកដាក់ទល់មុខគ្នា ។ ក៏ប៉ុន្តែ សូរិយាស៊ី បានសុំឲ្យខ្ញុំប្តូរទី

កន្លែងដោយរៀបតុរបស់គេ ចូលជ្រៅនៅខាងក្នុងបន្ទប់ ឯតុរបស់ខ្ញុំនៅក្បែរមាត់ទ្វារ ។ ខ្ញុំក៏យល់ព្រមរៀបចំតាមសំណើនោះ។ ក៏ប៉ុន្តែ ខ្ញុំនឹកក្នុងចិត្តថាគាត់នេះអាចគិតថា "ខ្ញុំមានជម្ងឺឆ្លងណាមួយហើយ ទើបគេមិនចង់ឲ្យនៅជិត ប្រហែលគេខ្លាចឆ្លងជម្ងឺអ្វីពីខ្ញុំទេដឹង?" តាមពិតនៅជំនាន់នោះ ខ្ញុំមានរូបរាងកាយស្គមស្គាំងម្យ៉ាងដោយសារការនឿយហត់ក្នុងការងារ និង ម្យ៉ាងទៀតទំនងជា នៅពេលនោះខ្ញុំពុំបានទទួលទានអាហារឲ្យគ្រប់គ្រាន់តាមតម្រូវការកាឡូរី ។ បន្ថែមលើពីនោះខ្ញុំក៏មានសម្បុរខ្មៅដូចជនជាតិអាហ្វ្រិកដែរ ។ ក៏ប៉ុន្តែនៅទីបំផុត សូរិយាសុី ក៏ក្លាយទៅជាមិត្តជិតស្និទ្ធម្នាក់របស់ខ្ញុំ ។ ការិយាល័យរបស់យើងទាំងពីរនាក់ នៅចន្លោះបន្ទប់ចោះកាតដែលមាននារីក្មេងៗ ជាអ្នកចោះដោយប្រើឧបករណ៏ទំនើបៗ និង ការិយាល័យរបស់លោក លៀស ចាន់ ថុន ។ ដូច្នេះហើយជាប់ជានិច្ច យើងត្រូវរំខានដោយសារការដើរឆ្លងកាត់មិនឈប់ឈររវាងលោកនាយ និង នារីក្មេងៗទាំងនោះ ។

ប៉ុន្មានខែក្រោយមក ខ្ញុំត្រូវបានបញ្ជូនឲ្យទៅរៀនវិជ្ជាផ្នែករៀបចំកម្មវិធី(Software Programmer) ដែលរៀបចំដោយក្រុមហ៊ុន អាយ ប៊ី អិម (IBM) ប្រចាំកម្ពុជា ។ ខ្ញុំប្រឡងជាប់តេស្ត ចូលរៀនពេលល្ងាចខាងផ្នែកភាសារៀបចំកម្មវិធី (Program language) ហៅថា ហ្គាប់ "Gap" សំរាប់កុំព្យូទ័រ អាយ ប៊ី អិម ៣៦០/២០ (IBM 360/20) ។ បន្ទាប់ពីបានទទួលលទ្ធផលថា ខ្ញុំបានជាប់តេស្តភ្លាម សូរិយាសុី បានប្រាប់ខ្ញុំថាខ្លួនគាត់ជាអ្នកផ្តល់អនុសាសន៏ឲ្យក្រុមហ៊ុន អាយ ប៊ី អិម ទទួលយកខ្ញុំឲ្យទៅរៀន ។ នៅទីបញ្ចប់នៃការរៀនសូត្រនោះ ខ្ញុំក៏អាចចេះសរសេរកម្មវិធីផ្នែកគណនេយ្យបានខ្លះៗ ។ នៅថ្ងៃទី ២៩ មិថុនា ១៩៧៣ ខ្ញុំក៏ប្រឡងជាប់វិញ្ញាបនប្រ័តដែលផ្តល់ឲ្យដោយក្រុមហ៊ុន អាយ ប៊ី អិម នៃប្រទេសកម្ពុជានោះ ។ ទោះបីជាខ្ញុំបានមកបំរើការងារថ្មីក្នុងមុខវិជ្ជាជីវៈថ្មីក៏ដោយ ក៏ខ្ញុំនៅជាប់

ជំពាក់ក្នុងការសិក្សាផ្នែកគណនេយ្យរបស់ខ្ញុំជានិច្ច ។ ខ្ញុំនៅតែព្យាយាមធ្វើការរៀនសូត្រតាមរយៈសំបុត្រឆ្លើយឆ្លងជាមួយគ្រឹះស្ថានសិក្សារបស់បារាំងតទៅទៀត ។

ដើម្បីឆ្លើយតបទៅនឹងអតិផរណា និង សេចក្តីត្រូវការនៃសាច់ប្រាក់ដែលចេះតែកើនឡើងនៅក្នុងពេលសង្គ្រាមនោះ ក្រុមហ៊ុនកូមិន្ទខ្មែរបានទទួលការអនុញ្ញាតពីរដ្ឋាភិបាល ឲ្យចេញបណ្ណ័ខ្ចីប្រាក់ដែលផ្តល់ការប្រាក់ខ្ពស់ ។ បន្ថែមលើនេះ ក្រុមហ៊ុនក៏មានរៀបចំពិធីចាប់ឆ្នោតជូនរង្វាន់ ដល់អ្នកដែលមានបណ្ណ័ខ្ចីប្រាក់របស់ក្រុមហ៊ុននោះ ។ កិច្ចប្រតិបត្តិការបែបនេះ មានប្រជាប្រិយខ្លាំងណាស់ និង បានទទួលជោគជ័យយ៉ាងខ្លាំងដោយសារប្រជាពលរដ្ឋ ដែលជាអ្នកមានប្រាក់កាសបបួលគ្នាមកទិញបណ្ណ័ខ្ចីប្រាក់មិនឈប់ឈរ ។ ក្រុមហ៊ុនក៏បានប្រែក្លាយទៅជាទីផ្សារហិរញ្ញវត្ថុដែលពួកអ្នកមាន ឬ អ្នកមានល្មមៗអាចយកប្រាក់មកវិនិយោគបាន ។ យ៉ាងនេះហើយ ទើបនៅជាន់ខាងក្រោមនៃការិយាល័យរបស់យើងមានពោរពេញទៅដោយអតិថិជន ដែលយកប្រាក់មកឲ្យក្រុមហ៊ុនខ្ចី ឬ ចូលមកស្តាប់លទ្ធផលនៃការចាប់ឆ្នោតយករង្វាន់ ។ ថ្នាក់ដឹកនាំក្រុមហ៊ុន មានភាពវៃឆ្លាតក្នុងការដោះស្រាយបញ្ហាហិរញ្ញវត្ថុ ដែលគ្មាននរណាជៀសរួចនៅក្នុងសង្គ្រាម ក៏ប៉ុន្តែពួកគេត្រូវទទួលបរាជ័យក្នុងការដោះស្រាយបញ្ហាផ្នែកសង្គម ។

# កូដកម្មដោយឥតប្រាប់មុន

ថ្ងៃមួយនៅពេលដែលខ្ញុំកំពុងតែរវល់យ៉ាងខ្លាំងក្នុងការងារ មានសហការីម្នាក់រត់មកប្រាប់យ៉ាងត្រហេបត្រហបថាទ្វារចេញចូលទាំងអស់ និង របងរបស់ក្រុមហ៊ុន ត្រូវក្រុមពួកសហជីពពលករបញ្ជាឲ្យចាក់សោរ ព្រោះពួកគេនាំគ្នាធ្វើកូដកម្ម ។ ខ្ញុំមានការងឿងឆ្ងល់យ៉ាងខ្លាំង ព្រោះខ្ញុំមិនដែលដឹង ពុំដែលឮថាមានសហជីពណាមួយនៅក្នុងក្រុមហ៊ុននោះឡើយ ។ម្យ៉ាងទៀត ពួកយើងក៏ពុំដែលបានទទួលការ

ណែនាំ ឬ ការផ្តល់ដំណឹងជាមុនៗនឹងមានកូដកម្មនោះទេ ។ តាមពិត នៅពេលមុននោះ រដ្ឋាភិបាលបានអនុញ្ញាតឲ្យមានការបង្កើតសហជីពពលករ ដែលដឹកនាំដោយទីប្រឹក្សាមួយរូបរបស់លោកប្រធានាធិបតី លន់ នល់ ដែលជាបញ្ញវន្តមួយរូបមកពីសហរដ្ឋអាមេរិក ក្នុងគោលដៅនយោបាយអ្វីមួយ ។ នៅពេលនោះរបប លន់ នល់ កំពុងជួបប្រទះនូវការបែកបាក់គ្នាយ៉ាងធ្ងន់ធ្ងរ ។ សូមបញ្ជាក់ថាបន្ទាប់ពីមានការកែប្រែរបបរាជានិយម មកជារបបសាធារណរដ្ឋវិញនោះ លោក លន់ នល់ បានប្រកាសខ្លួនឯងជាប្រធានាធិបតីនៃសាធារណរដ្ឋនៅឆ្នាំ ១៩៧២ ។ បន្ទាប់មកគាត់បានរៀបចំឲ្យមានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ដែលគាត់បានទទួលជ័យជំនះ ។ កូដកម្មបានបញ្ឈប់ការងាររបស់យើងទាំងអស់នៅក្នុងក្រុមហ៊ុន ។ ពួកយើងជួបជុំគ្នានៅក្នុងការិយាល័យរៀងៗខ្លួន នៅគ្រាដែលថ្នាក់ដឹកនាំក្រុមហ៊ុនជាប់រវល់និយាយទូរសព្ទ័ទាក់ទងមន្ត្រីរដ្ឋាភិបាលនានា ។ លោកប្រធានបុគ្គលិករបស់ក្រុមហ៊ុនបានប្រឹងប្រែងតាមលទ្ធភាពរបស់គាត់ ដើម្បីព្យាយាមចរចារកផ្លូវដោះស្រាយជាមួយពួកសហជីព ដែលជាកូដករទាំងនោះ តែពុំបានជោគជ័យ ។ ខ្ញុំព្យាយាមទូរសព្ទ័ទៅបងប្រុសខ្ញុំគឺ បងស៊ីនឿន នៅឯធនាគារជាតិកម្ពុជា តែក៏ពុំបានទទួលជោគជ័យដែរ ។ ដូច្នេះ ពួកក្រុមគ្រួសាររបស់យើង ក៏គ្មាននរណាដឹងដែរថា ចាប់តាំងពីម៉ោងបីរសៀលរហូតមក ពួកយើងត្រូវជាប់នៅក្នុងអាគាររបស់ក្រុមហ៊ុន មិនអាចចេញទៅណារួចបានឡើយ ។ ម្យ៉ាងទៀត នៅផ្ទះយើង ក៏យើងគ្មានទូរស័ព្ទប្រើដែរ ។ នៅពេលនោះ ក៏គ្មានអ្នកកាសែត ឬ អ្នកទូរទស្សន៍មកធ្វើការផ្សព្វផ្សាយភ្លាមៗនោះទេ ។ ដូច្នេះនៅពេលយប់ ទើបក្រុមគ្រួសាររបស់យើងចាប់ផ្តើមបារម្ភពីព្រឹត្តិការណ៍អ្វីមួយ ដែលជាឧបសគ្គមិនអាចឲ្យខ្ញុំត្រឡប់ទៅផ្ទះវិញបានដូចធម្មតា ។ ដោយខ្លាចខ្ញុំមានគ្រោះថ្នាក់ ដែលប៉ះពាល់ដល់សុវត្ថិភាពខ្ញុំនោះ ទើបបងប្រុសធំបង្អស់របស់ខ្ញុំគឺ បងឈឿន (ឬ បងនាង) និងប្រពន្ធរបស់គាត់នាំគ្នាជិះម៉ូតូយ៉ាង

ប្រញាប់ប្រញាល់ទាំងពីរនាក់ មករកខ្ញុំទាំងយប់នៅឯស្នាក់ការក្រុមហ៊ុន ។ នៅពេលនោះទើបពួកគាត់ដឹងថាពួកយើងត្រូវជាប់នៅក្នុងអាគារមិនអាចចេញទៅណារួច ។ ប៉ុន្តែជាសំណាងល្អ ប៉ុន្មាននាទីក្រោយមក ក្រុមសហជីពពលករនោះ ក៏បានទទួលបញ្ជាពីថ្នាក់ដឹកនាំរបស់ពួកគេឲ្យបញ្ឈប់កូដកម្ម និង បើកទ្វាររបងអាគារក្រុមហ៊ុនឡើងវិញ ។ យើងត្រឡប់ទៅផ្ទះវិញនៅវេលាម៉ោង ១០ យប់ ហើយកូដកម្មនោះក៏ចប់សព្វគ្រប់តែត្រឹមនោះទៅ ។

ខ្ញុំពុំបានយល់អំពីហេតុផល ដែលនាំឲ្យក្រុមសហជីពពលករបញ្ឈប់កូដកម្មនោះទេ ។ ក៏ប៉ុន្តែ ព្រឹត្តិការណ៍ដ៏ចៃដន្យនេះបានធ្វើឲ្យខ្ញុំនឹកគិតរកវិធីចាកចេញពីប្រទេសកម្ពុជាជាថ្មីឡើងវិញ ។ ពួកយើងចាប់ផ្ដើមជជែកគ្នាយ៉ាងហ្មត់ចត់អំពីគំរោងការរបស់ខ្ញុំ ក្នុងការចេញដំណើរទៅប្រទេសបារាំង ។ ក្រុមគ្រួសារយើងទាំងមូល បានយល់ស្របតាមបំណងរបស់ខ្ញុំ ។

## ទីបំផុតខ្ញុំសម្រេចចេញទៅស្រុកបារាំង

យុវនិស្សិត និង មន្ត្រីមួយចំនួនបានទទួលអាហារូបករណ៍ ពីប្រទេសដទៃឲ្យទៅបន្តការសិក្សា ឬ ធ្វើការហ្វឹកហាត់មុខវិជ្ជាជំនាញនានានៅឯបរទេស ។ ខ្ញុំបានសំរេចចិត្តថា ខ្ញុំនឹងចេញដំណើរទៅប្រទេសបារាំងដោយខ្លួនឯង ។ ខ្ញុំបានសន្សំប្រាក់មួយចំនួនល្មមអាចទិញសំបុត្រយន្តហោះបាន ។ ដើម្បីត្រៀមការរស់នៅរបស់ខ្ញុំឯប្រទេសបារាំង ខ្ញុំបានសរសេរសំបុត្រទៅសមាគម អេស សេ អេហ្វ (S C F) ក្នុងឋានៈខ្ញុំជាសមាជិកសកម្មរបស់សមាគម ដើម្បីស្នើសមាគមឲ្យជួយរកការងារធ្វើនៅប្រទេសបារាំងនោះ ។ សមាគម អេស សេ អេហ្វ បានផ្ដល់ដំបូន្មានឲ្យខ្ញុំថា ខ្ញុំត្រូវទៅសុំការងារខ្លួនឯងផ្ទាល់នៅឯប្រទេសបារាំង ព្រោះថានិយោជកត្រូវការធ្វើ

សំភាសន៍ ជាមុនសិន មុននឹងរើសយើងឲ្យចូលធ្វើការ ។ គេមិនអាចធ្វើសំភាសន៍បានទេ ប្រសិនបើយើងមិននៅក្នុងប្រទេសបារាំង ។

ដើម្បីទទួលការអនុញ្ញាតឲ្យទៅសិក្សានៅប្រទេសបារាំងដោយខ្លួនឯង ខ្ញុំត្រូវទៅសុំការអនុញ្ញាតពីក្រសួងអប់រំ ដើម្បីបញ្ជាក់ថាតើក្នុងការសិក្សានៅឯបរទេសរបស់ខ្ញុំនោះមានភាពត្រឹមត្រូវដែរឬទេ? និង ថាតើខ្ញុំមានសមត្ថភាពអាចទ្រទ្រង់ចំណាយនានារបស់ខ្ញុំក្នុងការសិក្សានោះឬទេ? ដោយសារបងប្រុសខ្ញុំគឺ បងស៊ីនឿន មានទំនាក់ទំនងល្អជាមួយក្រសួង ខ្ញុំក៏បានទទួលការអនុញ្ញាតដោយពុំមានបញ្ហាអ្វីធំដុំឡើយ ។ សូមបញ្ជាក់ថា នៅសម័យនោះ ជនជាតិខ្មែរណា ដែលមានបំណងចេញទៅក្រៅប្រទេស ត្រូវមានទិដ្ឋាការអនុញ្ញាតឲ្យចេញទៅក្រៅប្រទេស ពីក្រសួងមហាផ្ទៃជាមុនសិន ទើបស្ថានទូតនានាអាចផ្តល់ទិដ្ឋាការចូលទៅក្នុងប្រទេសរបស់គេនីមួយៗ ។

ខ្ញុំមិនទាន់មានលិខិតឆ្លងដែន និង គ្មានអត្តសញ្ញាណប័ណ្ណប្រចាំខ្លួននៅឡើយទេ ។ ដូច្នេះ ខ្ញុំត្រូវធ្វើឯកសារទាំងនេះនៅក្រសួងសន្តិសុខជាតិ ។ នៅសម័យនោះ ក្រុមប៉ូលីស និង អន្តោប្រវេសន៍ជាផ្នែកដែលមានរបៀបរបបការងារផ្នែកការិយាល័យដ៏សន្ធឹកសន្ធាប់ និង ជាផ្នែកដែលមានអំពើពុករលួយយ៉ាងធ្ងន់ធ្ងរ ។ ក៏ប៉ុន្តែដោយសារ បងស៊ីនឿន មានមិត្តភ័ក្រម្នាក់ជាអធិការប៉ូលីស ខ្ញុំក៏ពុំសូវពិបាកក្នុងការរត់ការនោះឡើយ ។ ខ្ញុំនៅចាំបានថានៅពេលទៅយកលិខិតឆ្លងដែន និងទិដ្ឋាការចេញក្រៅប្រទេសនោះ ខ្ញុំត្រូវកាន់ឯកសារទៅសុំចុះហត្ថលេខាពីមន្ត្រី ក្នុងប្រមាណម្ភៃការិយាល័យ ទំរាំបានចប់សព្វគ្រប់ ។ តាមធម្មតា ពលរដ្ឋខ្មែរសាមញ្ញត្រូវចំណាយប្រាក់យ៉ាងច្រើន មុននឹងទទួលឯកសារគ្រប់គ្រាន់ក្នុងការធ្វើដំណើរចេញទៅក្រៅប្រទេស ។ ដោយសារខ្ញុំមានឯកសារគ្រប់គ្រាន់ ខ្ញុំក៏បានទទួលទិដ្ឋាការពីស្ថានទូតបារាំងសំរាប់ការធ្វើដំណើររបស់ខ្ញុំ ។

# រៀបការបងប្រុសទី២

មុនពេលចេញដំណើរទៅប្រទេសបារាំងនោះ មានព្រឹត្តិការណ៍ដ៏សំខាន់មួយទៀតបានកើតឡើងនៅក្នុងគ្រួសាររបស់យើង ។ ក្រុមគ្រួសាររបស់យើងនឹងរៀបចំពិធីមង្គលការឲ្យបងប្រុសទី២របស់ខ្ញុំគឺ បងស៊ីនឿន ។ ករណីបងស៊ីនឿនមិនដូចបងទីមួយរបស់ខ្ញុំទេ ព្រោះបងស៊ីនឿន មិនបានស្គាល់អនាគតភរិយារបស់គាត់សោះឡើយ ។ កាលនោះ ម្តាយមីងរបស់ខ្ញុំគឺ អ្នកមីងសាម៉ុឌី បានផ្តល់គំនិតក្រោយពីបានសង្កេតយ៉ាងហ្មត់ចត់លើគ្រួសារមួយដែលនៅជិតខាង ហើយដែលមានទំនាក់ទំនងល្អជាមួយគ្នា ។ គ្រួសារនោះគឺ ជាគ្រួសាររបស់ចៅហ្វាយស្រុកម្នាក់ដែលមានឋានន្តរសក្តិរហូតដល់ថ្នាក់ឧត្តមមន្ត្រី ។ លោកចៅហ្វាយស្រុកជាមនុស្សមិនសូវមាត់ក តែរាក់ទាក់ និង មានសន្តានចិត្តល្អ ។ ប្រពន្ធរបស់គាត់ជាស្ត្រីមានប្រាជ្ញាហើយមានប្រភពចេញពីត្រកូលជាន់ខ្ពស់ ដែលមានឪពុកជាវេជ្ជបណ្ឌិតដ៏ល្បីល្បាញ ។ លោកស្រីប្រពន្ធចៅហ្វាយស្រុក ជាប្អូនបង្កើតរបស់លោក ហួត សម្បត្តិ ដែលធ្លាប់កាន់តំណែងច្រើនជងជារដ្ឋមន្ត្រី នៅក្នុងសម័យសង្គមរាស្ត្រនិយម ។ នៅពេលដែលមានរដ្ឋប្រហារខែ មីនា ១៩៧០ នោះ លោក ហួត សម្បត្តិ កំពុងកាន់តំណែងជាឯកអគ្គរាជទូតព្រះរាជាណាក្រកម្ពុជា ប្រចាំនៅអង្គការសហប្រជាជាតិ ។ នៅពេល បងស៊ីនឿន រៀបការនោះ លោក ហួត សម្បត្តិ កំពុងស្ថិតនៅទីក្រុងប៉េកាំងនៃប្រទេសចិន បំរើការងារជារដ្ឋមន្ត្រី នៃរដ្ឋាភិបាលនិរទេសរបស់សម្តេចសីហនុ ។ តែទោះបីជាមានបញ្ហាផ្នែកនយោបាយយ៉ាងនេះក៏ដោយ ក៏គ្រួសារលោកចៅហ្វាយស្រុកមានទំនាក់ទំនងល្អជាមួយលោក លន់ នល់ ដែរ ។ លោកចៅហ្វាយស្រុកមានកូនក្រមុំដ៏ស្រស់ស្អាតម្នាក់ឈ្មោះ ទេពធីតា ដែលកំពុងសិក្សានៅ សាលាប៉ឺទីលីសេ (Petit Lycée) ជាប់នឹងវិទ្យាល័យដេកាត ។ ម្តាយមីងខ្ញុំ និង

លោកស្រីប្រពន្ធចៅហ្វាយស្រុកយល់ស្របគ្នាថា បងស៊ីនឿន គួរតែរៀបការជាមួយនឹងទេពធីតា ។ ម្តាយមីងខ្ញុំ បាននាំពាក្យទៅជំរាបម្តាយខ្ញុំ ម្តាយខ្ញុំក៏ជំរាបទៅឪពុកខ្ញុំ ទីបំផុតទាំងអស់គ្នាព្រមព្រៀងលើការជ្រើសរើសនេះ លើកលែងតែសាម៉ីខ្លួនទាំងពីរដែលនៅមិនទាន់ស្គាល់គ្នានៅឡើយ ។ ដូច្នេះ មុននឹងសំរេចទៅស្តីដណ្តឹងទេពធីតា បងស៊ីនឿន និង បងនាងបានសាកល្បងលបទៅលួចមើលនាង ទេពធីតាជាមុនសិន ។

បងទាំងពីរនាក់នាំគ្នាជិះរថយន្តទៅលបមើលនាង ទេពធីតា ពីក្នុងឡាននៅឯប៉ឺទីលីសេ ។ បងស៊ីនឿន ទើបតែទិញរថយន្តចំណាស់មួយម៉ាកម៉ូស្កូវីត (Moscovit) ។ ចំពោះបង ស៊ីនឿន គ្រាន់តែឃើញភ្លាមក៏ចាប់ចិត្តស្រឡាញ់ភ្លែត ។ បងខ្ញុំទាំងពីរលបទៅមើល ទេពធីតា អស់រយៈពេលប្រហែលមួយសប្តាហ៍ ។ នៅទីបំផុតទាំងអស់គ្នាក៏សំរេចចិត្តរៀបមង្គលការមួយខែក្រោយមក ។ ចំពោះក្រុមគ្រួសារយើង ពិធីមង្គលការនេះជាពិធីដ៏ធំដុំមួយចុងក្រោយបង្អស់ មុននឹងអ្វីៗទាំងអស់ត្រូវវិនាសបាត់បង់ដោយសារសង្គ្រាម ។

ខ្ញុំសង្កេតឃើញ នៅក្នុងពិធីជប់លៀងមានមន្ត្រីធំៗជាច្រើនបានចូលរួម ។ ពិធីជប់លៀងដ៏ធំនោះ បានរៀបចំឡើងនៅភោជនីយដ្ឋានដ៏ល្បីល្បាញមួយឈ្មោះព្រះច័ន្ទពេញវង់ (La Lune) ។ បងស៊ីនឿន និង គ្រួសាររបស់ភរិយាគាត់មានការរាប់អានពីមន្ត្រីជាន់ខ្ពស់ជាច្រើន ដោយហេតុថា បងប្រុសខ្ញុំបានចូលរួមយ៉ាងសកម្មក្នុងគណបក្សប្រជាធិបតេយ្យ ។ គាត់ជាសមាជិកគណៈកម្មាធិការមួយរូបនៃគណបក្សនេះ ដែលជាគណបក្សប្រឆាំងយ៉ាងចេញមុខនឹងរបប លន់ នល់ ។ បងស៊ីនឿនត្រូវរាប់បញ្ចូលជាថ្នាក់ដឹកនាំយុវវ័យនៃគណបក្សប្រជាធិបតេយ្យ ។ ប្រសិនបើគណបក្សប្រជាធិបតេយ្យសម័យនោះត្រូវឡើងកាន់អំណាច បងប្រុសខ្ញុំប្រហែលជានឹងត្រូវបានតែងតាំង ក្នុងតំណែងរដ្ឋមន្ត្រីក្រសួងណាមួយមិនខានឡើយ ។

បន្ទាប់ពីពិធីមង្គលការបានចប់សព្វគ្រប់ហើយ បងស៊ីនឿន បានរើអីវ៉ាន់ ដែលមានតែខោអាវបន្តិចបន្តួចទៅរស់នៅជាមួយ ឪពុក ម្តាយក្មេករបស់គាត់ ។

# ថ្ងៃចុងក្រោយនៅកម្ពុជា

ខ្ញុំបន្តធ្វើការនៅកូមិន្ទខ្មែរ រហូតដល់ថ្ងៃខ្ញុំលាឈប់ពីការងារមួយថ្ងៃមុនពេលខ្ញុំចេញទៅប្រទេសបារាំង ។ ម្តាយខ្ញុំបានត្រៀមសាច់គោ និង សាច់ជ្រូកងៀតដោយបារម្ភខ្លាចខ្ញុំពុំមានអ្វីបរិភោគនៅឯប្រទេសឆ្ងាយ ។ ឪពុកខ្ញុំ ត្រួតពិនិត្យយ៉ាងល្អិតល្អន់នូវសំលៀកបំពាក់ក្នុងវ៉ាលី ហើយផ្តាំថាកុំភ្លេចយកអង្ករទៅជាមួយ ។ ថ្ងៃដែលខ្ញុំត្រូវចេញដំណើរគឺ នៅថ្ងៃទី ៥ សីហា ១៩៧៣ ។ ឪពុកខ្ញុំ ហៅខ្ញុំមកជិតដោយមានធូបបីសរសៃកាន់នៅជាប់នឹងដៃ ។ ខ្ញុំក្រាបថ្វាយបង្គំឪពុកម្តាយខ្ញុំបីដងដើម្បីទទួលនូវពរជ័យតាមប្រពៃណីខ្មែរ ។ បងស៊ីនឿន ជាអ្នកចាត់ចែងខាងផ្នែកសំបុត្រយន្តហោះ និង កិច្ចការផ្នែករដ្ឋបាលដូចជាទិដ្ឋាការ និង លិខិតឆ្លងដែនជាដើម ។ បងនាង បងទីមួយរបស់ខ្ញុំ ត្រៀមទឹកក្តៅស្រោចឲ្យខ្ញុំងូត ដើម្បីឲ្យបានស្រួលខ្លួន មុននឹងធ្វើដំណើរទៅឆ្ងាយ ។ ក៏ប៉ុន្តែ មុននឹងយើងចេញដំណើរចេញពីផ្ទះនោះ យើងបានទទួលដំណឹងថាជើងយន្តហោះរបស់យើងត្រូវពន្យារទៅថ្ងៃទី ៦ សីហា ១៩៧៣ វិញ ។ នៅថ្ងៃចុងក្រោយនេះ ខ្ញុំក៏ក្រាបថ្វាយបង្គំឪពុកម្តាយខ្ញុំបីដងដូចមុនទៀត និង ជំរាបលាលោកទាំងពីរទាំងក្តីអាល័យ ។ នោះជាឱកាសចុងក្រោយ ដែលខ្ញុំបានសំដែងនូវការគោរពចំពោះឪពុកដ៏ជាទីស្រឡាញ់របស់ខ្ញុំ ។ បងនាង ត្រៀមទឹកក្តៅឲ្យខ្ញុំងូតជាថ្មីម្តងទៀតនោះគឺ ជាការស្រឡាញ់ចុងក្រោយរបស់គាត់ចំពោះខ្ញុំ ។

នៅឯចំណតអាកាសយានដ្ឋានពោធិចិនតុង មានមនុស្សម្នាច្រើនណែនណាន់ មានទាំងវត្តមានអ្នកធ្វើដំណើរ និង ទាំងអ្នកជូនដំណើរផង ។ អ្នកខ្លះយំលា

ឪពុកម្តាយ ញាតិមិត្ត ឬ កូនចៅដែលបែកចេញទៅ ។ ឪពុកម្តាយខ្ញុំ បងប្អូនខ្ញុំលើកលែងតែស៊ីថានចេញ សុទ្ធតែបានមកជូនដំណើរខ្ញុំនៅព្រលានយន្តហោះពោធិចិនតុងទាំងអស់ ។

ដូច្នេះ នៅពេលដែលខ្ញុំមានអាយុ ២៣ ឆ្នាំ ខ្ញុំក៏បែកចេញពីប្រទេសកម្ពុជាដោយមានប្រាក់កាសបន្តិចបន្តួចគឺ ប្រមាណ ៣០០ ដុល្លារ និង អង្ករ ១៥ គីឡូក្រាម សាច់ងៀត ព្រមទាំងសំលៀកបំពាក់ខ្លះៗតែប៉ុណ្ណោះ ។ នៅពេលដែលខ្ញុំចូលទៅក្នុងយន្តហោះ ខ្ញុំក៏លែងឃើញមុខឪពុក បង ប្អូនខ្ញុំទាំងបួននាក់គឺ បងឈឿន បងស៊ីនឿន ប្អូនប្រុសណារីន វុធធៀន តទៅទៀតជារៀងរហូត ។ នៅពេលនោះខ្ញុំមិនបាននឹកថាដំណើររបស់ខ្ញុំនេះមានរយៈពេលជាងម្ភៃឆ្នាំឯណោះ ទើបខ្ញុំអាចវិលមកមាតុប្រទេសរបស់ខ្ញុំវិញ ។ ខ្ញុំមិនដែលនឹកឃើញថា ប្រទេសកម្ពុជាក្លាយទៅជាទីកន្លែងនៃមហាសោកនាដកម្មដ៏ធំធេងមួយ ដែលបានបំផ្លាញជីវិតជនស្លូតត្រង់រាប់លាននាក់យ៉ាងនេះសោះ ។ ខ្ញុំមិនដែលនឹកថាបដិវត្តន៍នៃប្រទេសកម្ពុជាបានបំផ្លិចបំផ្លាញសង្គមជាតិយើងឲ្យរលត់រលាយយ៉ាងដូច្នេះឡើយ ។

យុវវ័យរបស់ខ្ញុំ បានស្ថិតនៅក្រោមការគាបសង្កត់នៃវាសនារបស់ប្រទេសជាតិ ក្នុងយុគសម័យមួយ ដែលមិនអាចប្រមើលអនាគតបាន ។ ក៏ប៉ុន្តែ ឆាកដំបូងនៃជីវិតនេះ ក៏បានឆ្លុះបង្ហាញនូវការប្តេជ្ញាចិត្តឆ្ពោះទៅមុខជានិច្ចរបស់ខ្ញុំដែរ ។ សេចក្តីស្នេហា ឬ ព្រហ្មវិហារធម៌របស់ឪពុកម្តាយខ្ញុំមកលើរូបខ្ញុំ និង ការជួយទំនុកបំរុងរបស់ក្រុមគ្រួសារបងប្អូនញាតិមិត្តខ្ញុំ បានក្លាយជាប្រភពថាមពលដើម្បីឲ្យខ្ញុំអាចពុះពារគ្រប់ឧបសគ្គ និង អាចឆ្លងកាត់នូវរាល់ការលំបាកទាំងឡាយ ។ ខ្ញុំពុំអាចបំភ្លេចបានឡើយនូវបទពិសោធន៍ដ៏មានតម្លៃ ក្នុងវគ្គដំបូងនៃជីវិតនេះ ។